Australian Government

ភាពជាពលរដ្ឋអូស្ត្រាលី ៖

ចំណងរួមរបស់យើង

ព័ត៌មានទាំងអស់ដែលលោកអ្នកត្រូវការដើម្បីអង្គុយប្រឡងចូលសញ្ជាតិអូស្ត្រាលីមាននៅក្នុងសៀវភៅនេះ ។ លោកអ្នកមិនត្រូវការទិញ ឬក៏រកកញ្ចប់ព័ត៌មានស្ដីពីការប្រឡងចូលសញ្ជាតិផ្សេងទៀតពីបុគ្គល ឬអង្គការណាមួយឡើយដើម្បីឱ្យបានជាប់ការប្រឡងចូលសញ្ជាតិ ។ ក្រសួងមិនគាំទ្រ ឬណែនាំឱ្យប្រើកញ្ចប់ព័ត៌មានណាមួយឡើយដែលអះអាងថាវានឹងជួយលោកអ្នកឱ្យបានប្រឡងចូលសញ្ជាតិជាប់ ។

© Commonwealth of Australia 2020

ក្រៅពីសញ្ញាជាតិកុំម៉ន់វេល សម្ភារៈទាំងអស់ដែលមាននៅក្នុងការបោះពុម្ពផ្សាយនេះ ត្រូវបានផ្ដល់ជូនទៅតាមអាជ្ញាប័ណ្ណអន្តរជាតិមាត្រាទី ៤.0 ស្ដីពីការចែកចាយកម្មសិទ្ធរបស់ក្រុមហ៊ុន Creative Commons នៅ https://creativecommons.org/licenses/by/4.0/legalcode ។

នេះមានន័យថាអាជ្ញាប័ណ្ណនេះអនុវត្តបានតែចំពោះសម្ភារៈដែលបានចែងនៅក្នុងឯកសារនេះទេ ។

ព័ត៌មានលម្អិតស្ដីពីលក្ខខណ្ឌអាជ្ញាប័ណ្ណដែលពាក់ព័ន្ធមាននៅក្នុងវ៉ិបសាយថ៍ក្រុមហ៊ុន Creative Commons នៅ https://creativecommons.org/ ជាក្រមច្បាប់ពេញលេញសម្រាប់អាជ្ញាប័ណ្ណមាត្រាទី ៤.0 របស់ក្រុមហ៊ុន Creative Commons នៅ https://creativecommons.org/licenses/by/4.0/legalcode ។

ការប្រើប្រាស់សញ្ញាជាតិ

លក្ខខណ្ឌដែលអាចប្រើប្រាស់សញ្ញាជាតិបានគឺមានរៀបរាប់លម្អិតនៅវ៉ិបសាយថ៍របស់ក្រសួងនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី —https://www.pmc.gov.au/government/commonwealth-coat-arms.

សូមទាក់ទងយើង

ការសាកសួរនានាទាក់ទងនឹងអាជ្ញាប័ណ្ណ និងការប្រើប្រាស់ឯកសារនេះតាមវិធីណាមួយ
សូមស្វាគមន៍នៅ ៖

សាខាទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយរបស់
ក្រសួងសន្តិសុខជាតិ
PO Box 25
BELCONNEN ACT 2616

សេចក្ដីបដិសេធការទទួលខុសត្រូវ

សូមជម្រាបជូនដល់អ្នកអានជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះច័រវិសស្រ្តេត (Torres Strait) ជាមុនថា ការបោះពុម្ពផ្សព្វផ្សាយនេះមានរូបភាព និង/ឬក៏ខ្លឹមសារដែលទាក់ទងនឹងអ្នកដែលបានស្លាប់ទៅហើយ ។

មាតិការឿង

សារចំពោះលោកអ្នក 2

ផ្នែកដែលអាចយកមកប្រឡង

ផ្នែកទី 1 ៖ ប្រទេសអូស្ត្រាលី និងជនជាតិរបស់ខ្លួន 7

ផ្នែកទី 2 ៖ ជំនឿលើលទ្ធិប្រជាធិបតេយ្យ សិទ្ធិ និងសេរីភាពរបស់ប្រទេសអូស្ត្រាលី 17

ផ្នែកទី 3 ៖ រដ្ឋាភិបាល និងច្បាប់នៅក្នុងប្រទេសអូស្ត្រាលី 23

ផ្នែកទី 4 ៖ គុណតម្លៃរបស់ប្រទេសអូស្ត្រាលី 33

សន្ទានុក្រមនៃផ្នែកដែលអាចយកមកប្រឡង 40

ផ្នែកដែលមិនយកមកប្រឡង

ផ្នែកទី 5 ៖ ប្រទេសអូស្ត្រាលីក្នុងពេលបច្ចុប្បន្ននេះ 48

ផ្នែកទី 6 ៖ ប្រវត្តិនៃជនជាតិអូស្ត្រាលីរបស់យើង 63

សន្ទានុក្រមនៃផ្នែកដែលមិនយកមកប្រឡង 84

សម្រាប់ព័ត៌មានបន្ថែម 86

សេចក្តីថ្លែងអំណរគុណ 88

សារចំពោះលោកអ្នក

សូមអបអរសាទរចំពោះការជ្រើសរើសដើម្បីក្លាយជាពលរដ្ឋអូស្ត្រាលី ។ ការជ្រើសរើសនេះត្រូវការសេចក្ដីក្លាហាន ការប្រឹងប្រែង និងការប្ដូរផ្ដាច់ ដើម្បីរស់នៅក្នុងប្រទេសថ្មី និងចូលរួមយ៉ាងពេញទំហឹងក្នុងនាមជាពលរដ្ឋម្នាក់ ។ យើងឱ្យតម្លៃដល់ការផ្ដល់វិភាគទានរបស់លោកអ្នកដល់សង្គមរបស់យើងដែលពោពេញទៅដោយសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ ។

ភាពជាពលរដ្ឋអូស្ត្រាលីគឺជាជំហានសំខាន់មួយនៅក្នុងប្រវត្តិអន្តោប្រវេសន៍របស់លោកអ្នក ។ ការក្លាយជាពលរដ្ឋអូស្ត្រាលីម្នាក់មានន័យថាលោកអ្នកកំពុងតែធ្វើការប្ដេជ្ញាជាបន្តទៀតចំពោះប្រទេសអូស្ត្រាលី និងគុណតម្លៃរួមរបស់យើង ។ វាក៏ជាការចាប់ផ្ដើមនៃសមាជិកភាពនៅក្នុងសហគមន៍អូស្ត្រាលីជាផ្លូវការរបស់លោកអ្នកផងដែរ ។ វាជាជំហានដែលនឹងអាចឱ្យលោកអ្នកនិយយថា ‘ខ្ញុំជាជនជាតិអូស្ត្រាលី’ ។

ភាពជាពលរដ្ឋអូស្ត្រាលីគឺជាអភ័យឯកសិទ្ធិមួយដែលផ្ដល់ជូនរង្វាន់យ៉ាងសម្បើម ។ ដោយក្លាយជាពលរដ្ឋអូស្ត្រាលី លោកអ្នកកំពុងតែចូលរួមក្នុងសហគមន៍ជាតិមួយដែលមានលក្ខណៈប្លែកខុសពីគេ ។ ប្រទេសរបស់យើងត្រូវបានកសាងឡើងដោយមានការផ្ដល់វិភាគទានរបស់ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្ត្រេត (Torres Strait) ស្ថាប័នប្រជាធិបតេយ្យដែលយើងបានទទួលមរតកពីចក្រភពអង់គ្លេស ហើយនិងជនចំណាកស្រុកមកពីទូទាំងពិភពលោក ។ យើងធ្វើពិធីអបអរសាទរចំពោះភាពចម្រុះនៃជនជាតិរបស់យើង ហើយក្នុងពេលជាមួយគ្នានេះដែរ ការខំប្រឹងប្រែងដើម្បីបង្កើតប្រជាជាតិមួយដែលមានការរួបរួម និងភាពចុះសម្រុងគ្នា ។

ចំណុចខ្លាំងរបស់សហគមន៍គឺថាយើងធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហានានា និងដើម្បីកសាងអនាគតរបស់ប្រទេសអូស្ត្រាលី ។ យើងមានប្រព័ន្ធរដ្ឋាភិបាលដែលមានស្ថេរភាព ហើយជនជាតិអូស្ត្រាលីគោរពអាជ្ញាធរ និងច្បាប់របស់រដ្ឋាភិបាល ។ ស្ថេរភាពរបស់យើង វប្បធម៌របស់យើង ហើយនិងច្បាប់របស់យើងត្រូវបានរៀបចំឡើងដោយប្រវត្តិសាស្ត្ររបស់យើង ។ ដោយបានចូលរួមនៅក្នុងសហគមន៍អូស្ត្រាលី លោកអ្នកនឹងបន្ថែមទៅលើប្រវត្តិនៃប្រទេសអូស្ត្រាលី ហើយលោកអ្នកនឹងប្រកាន់គោលជំហរជួយរៀបចំសហគមន៍នេះ ។

ប្រទេសអូស្ត្រាលីគឺជាទឹកដីដ៏ចំណាស់មួយ ។ វាមានទំហំធំល្វឹងល្វើយ និងលក្ខណៈប្លែកខុសពីគេ ។ វាជាប្រទេសមួយដែលមានព្រៃទឹកភ្លៀង និងតំបន់វាលភក់ ឆ្នេរសមុទ្រ និងវាលខ្សាច់ ហើយនិងមានទីក្រុង និងកសិដ្ឋាន ។ វប្បធម៌ជនជាតិដើមរបស់យើងគឺជាវប្បធម៌ចំណាស់ជាងគេបំផុតនៅក្នុងពិភពលោកដែលបានបន្តទុកមក ។ យើងក៏ជាប្រជាជាតិក្មេងខ្ចីផងដែរ ប្រជាជាតិនៃជនចំណាកស្រុក ។ ការតាំងលំនៅដ្ឋានរបស់ជនជាតិអឺរ៉ុបក្នុងប្រទេសអូស្ត្រាលីបានចាប់ផ្ដើមនៅឆ្នាំ 1788 និងយើងបន្តស្វាគមន៍ទទួលជនចំណាកស្រុកថ្មីនៅពេលបច្ចុប្បន្ននេះ ។

ប្រជាជនដែលមកពីប្រទេសជាង 200 បានទទួលយកប្រទេសអូស្ត្រាលីធ្វើជាផ្ទះរបស់ពួកគេ ។ ដោយហេតុនេះ សង្គមរបស់យើងគឺជាសង្គមដែលមានភាពចម្រុះជាតិសាសន៍ច្រើនជាងគេមួយនៅក្នុងពិភពលោក ។ ប្រទេសអូស្ត្រាលីបញ្ចូលភាពចម្រុះនៃជនជាតិ និងវប្បធម៌ជាមួយនឹងឯកភាពជាតិប្រកបដោយជោគជ័យ ។ ភាពជាពលរដ្ឋគឺជាចំណងរួមដែលបានបង្រួបបង្រួមយើងទាំងអស់គ្នា ។

អូស្ត្រាលីជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ ។ ភាពជាពលរដ្ឋផ្ដល់ដល់លោកអ្នកនូវឱកាសដើម្បីចូលរួមយ៉ាងពេញទំហឹងនៅក្នុងការ កសាងប្រជាជាតិប្រកាន់លទ្ធិប្រជាធិបតេយ្យរបស់យើង ។ នេះមានន័យថាលោកអ្នកបានប្រុងប្រៀបខ្លួនជាស្រេចដើម្បីបំពេញនូវការទទួលខុសត្រូវ របស់លោកអ្នកក្នុងនាមជាសមាជិកផ្លូវការម្នាក់នៃសហគមន៍អូស្ត្រាលី ។ ជនជាតិអូស្ត្រាលីមានជំនឿលើគុណតម្លៃរួម ដូចជាភាពថ្លៃថ្នូរ និងសេរីភាពរបស់មនុស្សម្នាក់ៗ សមភាពរវាងបុរស និងស្ត្រី ហើយនិងលើនីតិរដ្ឋ ។ ភាពជាពលរដ្ឋអូស្ត្រាលីគឺនិយាយអំពីការរស់នៅដោយប្រកាន់ខ្ជាប់នូវគុណតម្លៃទាំងនេះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

ការក្លាយជាពលរដ្ឋអូស្ត្រាលីម្នាក់

ការក្លាយជាពលរដ្ឋអូស្ត្រាលីម្នាក់គឺជាលំនាំសំខាន់មួយដែលមនុស្សធ្វើការសច្ចាប្រណិធានភក្ដីភាពរបស់ពួកគេដល់ប្រទេសអូស្ត្រាលី និងប្រជាជនអូស្ត្រាលី ហើយនិងបន្ទាប់មកមានសិទ្ធិអនុវត្តសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាពលរដ្ឋម្នាក់នៃប្រជាជាតិរបស់យើង ។

ការប្រឡងចូលសញ្ជាតិអូស្ត្រាលី

ការប្រឡងចូលសញ្ជាតិអូស្ត្រាលីត្រូវបានរៀបចំឡើងដើម្បីវាយតម្លៃថាតើលោកអ្នកមានចំណេះដឹងពីប្រទេសអូស្ត្រាលីប្រព័ន្ធប្រជាធិតេយ្យរបស់អូស្ត្រាលី ជំនឿ និងគុណតម្លៃ ហើយនិងការទទួលខុសត្រូវ និងអភ័យឯកសិទ្ធនៃភាពជាពលរដ្ឋអូស្ត្រាលីគ្រប់គ្រាន់ឬនៅ ។

ការប្រឡងចូលសញ្ជាតិគឺជាការប្រឡងដោយប្រើសំណួរដែលមានចម្លើយច្រើនសម្រាប់ជ្រើសរើសតាមប្រព័ន្ធកុំព្យូទ័រជាភាសាអង់គ្លេស ។ ការប្រឡងនេះមាន 20 សំណួរដែលបានជ្រើសរើសដោយចៃដន្យ ហើយចាប់ពីថ្ងៃទី15 ខែវិច្ឆិកា ឆ្នាំ2020 តទៅ ការប្រឡងក៏នឹងដាក់បញ្ចូលសំណួរស្ដីពីគុណតម្លៃរបស់ប្រទេសអូស្ត្រាលី ចំនួន 5 នៅក្នុងការប្រឡង ។

ដើម្បីប្រឡងជាប់ លោកអ្នកត្រូវឆ្លើយសំណួរស្ដីពីគុណតម្លៃទាំងប្រាំត្រូវទាំងអស់ ដោយបានពិន្ទុយ៉ាងតិចបំផុតត្រឹម 75 ភាគរយនៃសំណួរទាំងអស់ ។

ការប្រលងចូលសញ្ជាតិត្រូវបានធ្វើឡើងនៅតាមការិយាល័យនានានៃក្រសួងសន្តិសុខជាតិនៅជុំវិញប្រទេសអូស្ត្រាលី ។ ការប្រឡងក៏ត្រូវបានរៀបចំតាមពេលវេលាកំណត់ផងដែរនៅតាមទីតាំងនានានៅទូទាំងតំបន់ជនបទនៃប្រទេសអូស្ត្រាលី ហើយនិងនៅតាមបេសកម្មក្រៅប្រទេសមួយចំនួន ។

ការត្រៀមប្រឡងចូលសញ្ជាតិអូស្ត្រាលី

ដើម្បីត្រៀមប្រឡងចូលសញ្ជាតិអូស្ត្រាលី លោកអ្នកនឹងត្រូវការអានសៀវភៅធនធាននេះ *ភាពជាពលរដ្ឋអូស្ត្រាលី ៖ ចំណងរួមរបស់យើង*

សៀវភៅធនធាននេះមានផ្នែកដែលអាចយកមកប្រឡង និងផ្នែកដែលមិនយកមកប្រឡង ។

ផ្នែកដែលអាចយកមកប្រឡង

ព័ត៌មានទាំងអស់ដែលលោកអ្នកត្រូវការយល់ដឹងដើម្បីប្រឡងចូលសញ្ជាតិជាប់គឺមាននៅក្នុងផ្នែកទាំងបួនដំបូងនៃសៀវភៅនេះ ៖

- ផ្នែកទី 1—ប្រទេសអូស្ត្រាលី និងជនជាតិរបស់ខ្លួន
- ផ្នែកទី 2—ជំនឿរួមលើលទ្ធិប្រជាធិបតេយ្យ សិទ្ធិ និងសេរីភាពនៃប្រទេសអូស្ត្រាលី
- ផ្នែកទី 3—រដ្ឋាភិបាល និងច្បាប់នៅក្នុងប្រទេសអូស្ត្រាលី
- ផ្នែកទី 4—គុណតម្លៃរបស់ប្រទេសអូស្ត្រាលី

លោកអ្នកនឹងត្រូវការយល់ដឹងពីព័ត៌មាននៅក្នុងផ្នែកដែលអាចយកមកប្រឡងដើម្បីឆ្លើយសំណួរនៅក្នុងការប្រឡងចូលសញ្ជាតិ ។

ផ្នែកដែលមិនយកមកប្រឡង

ផ្នែកដែលមិនយកមកប្រឡងមានព័ត៌មានសំខាន់ៗដើម្បីជួយលោកអ្នកឱ្យយល់ពីប្រវត្តិសាស្ត្រ និងវប្បធម៌នៃប្រទេអូស្ត្រាលី ។ ក្រសួងមិនធ្វើតេស្តលោកអ្នកទៅលើព័ត៌មាននេះទេ ។

- ផ្នែកទី 5—ប្រទេសអូស្ត្រាលីនាពេលបច្ចុប្បន្ន
- ផ្នែកទី 6—ប្រវត្តិនៃជនជាតិអូស្ត្រាលីរបស់យើង

សំណួរសម្រាប់អនុវត្ត

នៅចុងបញ្ចប់នៃផ្នែកដែលអាចយកមកប្រឡង មានសំណួរចំនួន 20 សម្រាប់ឱ្យលោកអ្នកអនុវត្តដើម្បីជួយលោកអ្នកត្រៀមប្រឡងចូលសញ្ជាតិ ។

សន្ទានុក្រម

មានសន្ទានុក្រម (បញ្ជីរាយពាក្យសំខាន់ៗ និងអត្ថន័យរបស់វា) នៅចុងបញ្ចប់នៃផ្នែកទាំងពីរ ផ្នែកដែលអាចយកមកប្រឡង និងផ្នែកដែលមិនយកមកប្រឡង ។

ព័ត៌មានបន្ថែម

លោកអ្នកអាចស្វែងរកយោបល់ស្ដីពីទីកន្លែងដែលលោកអ្នកអាចរកព័ត៌មានបន្ថែមបាននៅខាងក្រោយនៃសៀវភៅធនធាននេះ ។

ជំនួយក្នុងអំឡុងពេលប្រឡងចូលសញ្ជាតិ

យើងរំពឹងថាពលរដ្ឋដែលបម្រុងនឹងក្លាយជាពលរដ្ឋអូស្ត្រាលីភាគច្រើននឹងត្រូវចេះអាន និងសរសេរភាសាអង់គ្លេសដែលចាំបាច់ដើម្បីបំពេញការប្រឡងចូលសញ្ជាតិដោយមិនបាច់ត្រូវការជំនួយ ។ បច្ចេកវិទ្យាដែលបន្លែងអក្សរទៅជាសម្លេងដែលលោកអ្នកអាចប្រើដើម្បីស្តាប់សំណួរ និងជម្រើសនៃចម្លើយក៏មានសម្រាប់លោកអ្នកដែរ ។

បន្ទាប់ពីការប្រឡងចូលសញ្ជាតិអូស្ត្រាលី

ប្រសិនបើលោកអ្នកប្រឡងជាប់ យើងនឹងបន្តពិនិត្យមើលពាក្យសុំចូលសញ្ជាតិរបស់លោកអ្នក ។ ប្រសិនបើពាក្យសុំចូលសញ្ជាតិរបស់លោកអ្នកបានទទួលការយល់ព្រម ហើយលោកអ្នកនឹងត្រូវចូលរួមពិធីចូលសញ្ជាតិ លោកអ្នកនឹងទទួលបាននូវលិខិតអញ្ជើញឱ្យចូលរួមពិធីនេះ ។ ជាទូទៅ ពិធីរបស់លោកអ្នកនឹងប្រព្រឹត្តទៅក្នុងរយៈពេលប្រាំមួយខែចាប់ពីពេលដែលពាក្យសុំចូលសញ្ជាតិរបស់លោកអ្នកបានទទួលការយល់ព្រម ។

ការសច្ចាប្រណិធានចូលសញ្ជាតិអូស្ត្រាលី

វាជាការសំខាន់សម្រាប់ពលរដ្ឋអូស្ត្រាលីទាំងអស់ដើម្បីយល់ដឹងពីការទទួលខុសត្រូវ និងអភ័យឯកសិទ្ធនានា ហើយនិងអត្ថន័យនៃការក្លាយជាពលរដ្ឋអូស្ត្រាលីមួយរូប ថាតើយើងជាជនជាតិអូស្ត្រាលីតាមកំណើត ឬក៏តាមជម្រើស ។ នេះមានសារៈសំខាន់ណាស់ដល់ភាពជោគជ័យជាបន្តនៃប្រជាជាតិរបស់យើង ។

នៅពេលលោកអ្នកចូលរួមពិធីចូលសញ្ជាតិអូស្ត្រាលី លោកអ្នកនឹងធ្វើសច្ចាប្រណិធានចូលសញ្ជាតិអូស្ត្រាលី ។

ដោយបានធ្វើសច្ចាប្រណិធានដូច្នេះ លោកអ្នកកំពុងធ្វើការប្តេជ្ញាជាសាធារណៈចំពោះប្រទេសអូស្ត្រាលី និងកំពុងទទួលយកនូវការទទួលខុសត្រូវ និងអភ័យឯកសិទ្ធិនានានៃភាពជាពលរដ្ឋអូស្ត្រាលី ។

នេះគឺជាការសច្ចាប្រណិធានដែលលោកអ្នកនឹងធ្វើ ៖

*ចាប់ពីពេលនេះតទៅ នៅក្រោមព្រះជាម្ចាស់ **

ខ្ញុំសូមធ្វើសច្ចាប្រណិធាននូវភក្តីភាពរបស់ខ្ញុំចំពោះប្រទេសអូស្ត្រាលី ហើយនិងប្រជាជនអូស្ត្រាលី

ខ្ញុំសូមចូលរួមចំណែកក្នុងជំនឿលើលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសអូស្ត្រាលី

ខ្ញុំសូមគោរពសិទ្ធិ និងសេរីភាពរបស់ប្រទេសអូស្ត្រាលី

ខ្ញុំសូមប្រកាន់ខ្ជាប់ និងគោរពច្បាប់របស់ប្រទេសអូស្ត្រាលី ។

* លោកអ្នកអាចជ្រើសរើសថាតើលោកអ្នកត្រូវ ឬមិនត្រូវប្រើពាក្យ "នៅក្រោមព្រះជាម្ចាស់" ។

នៅពេលលោកអ្នកអានសៀវភៅនេះ លោកអ្នកនឹងទទួលបានការយល់ដឹងប្រសើរជាងមុនស្តីពីអត្ថន័យនៅពីខាងក្រោយនៃការសច្ចាប្រណិធាននេះ ហើយនិងរបៀបដែលលោកអ្នកអាចបំពេញតួនាទីរបស់លោកអ្នកឱ្យបានប្រសើរឡើងនៅក្នុងសង្គមអូស្ត្រាលី ។

ពិធីចូលសញ្ជាតិអូស្ត្រាលី

ពិធីចូលសញ្ជាតិអូស្ត្រាលីអាចជាពិធីតូចដោយមានមនុស្សចូលរួមបន្តិចបន្តួច ឬក៏ជាពិធីដ៏ធំដែលមានមនុស្សចូលរួមរាប់រយនាក់ ឬក៏ឈានដល់រាប់ពាន់នាក់ផង ។ ជម្រៅនៃអារម្មណ៍ និងមោទនភាពក្នុងចំណោមពលរដ្ឋថ្មី និងមន្ត្រីផ្លូវការធ្វើឱ្យពិធីនេះពោពេញទៅដោយភាពសប្បាយរីករាយ ។

នៅពេលចាប់ផ្តើមនៃពិធីចូលសញ្ជាតិ លោកអ្នកអាចទទួលបានការស្វាគមន៍ពីអ្នកតំណាងនៃជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្រ្តេត (Torres Strait) ដែលជាម្ចាស់ប្រពៃណីនៃទឹកដីនៅក្នុងតំបន់របស់លោកអ្នក ។ ការស្វាគមន៍មកកាន់ពិធីការរបស់ប្រទេសបាន និងកំពុងអនុវត្តដោយជនជាតិដើមអូស្ត្រាលី នៅលើមាតុភូមិប្រពៃណីរបស់ពួកគេរាប់ពាន់ឆ្នាំមកហើយ ។ លោកអ្នកនឹងឮនូវពាក្យស្វាគមន៍ និងការលើកទឹកចិត្តពីអ្នកដឹកនាំដទៃទៀតនៃសហគមន៍ ឬក៏តំណាងរដ្ឋាភិបាលមូលដ្ឋានរបស់លោកអ្នក ។

លោកអ្នកនឹងអាន ឬថាតាមពាក្យសច្ចាប្រណិធានចូលសញ្ជាតិអូស្ត្រាលីយ៉ាងខ្លាំងៗ ជាមួយមនុស្សដទៃទៀតដែលបានជ្រើសរើសដើម្បីក្លាយជាពលរដ្ឋអូស្ត្រាលី ។ នេះគឺជាផ្នែកសំខាន់បំផុតនៃពិធីនេះ ។ លោកអ្នកមិនក្លាយជាពលរដ្ឋអូស្ត្រាលី រហូតដល់លោកអ្នកបានធ្វើសច្ចាប្រណិធាននូវការប្តេជ្ញាចំពោះប្រទេសអូស្ត្រាលី ។

លោកអ្នកត្រូវបានស្វាគមន៍ឱ្យយកគម្ពីរព្រះ ឬគម្ពីរគ្រីស្តសាសនាដើម្បីកាន់នៅអំឡុងពេលលោកអ្នកធ្វើសច្ចាប្រណិធាន ប៉ុន្តែលោកអ្នកមិនចាំបាច់ត្រូវធ្វើដូច្នេះទេ ។

អ្នកដឹកនាំមកពីសហគមន៍របស់លោកអ្នក ឬតំណាងរដ្ឋាភិបាលនឹងធ្វើសុន្ទរកថាខ្លីៗ ស្តីពីអត្ថន័យនៃភាពជាពលរដ្ឋ ។ លោកអ្នកនឹងទទួលបានសំបុត្រសញ្ជាតិអូស្ត្រាលី ហើយលោកអ្នកក៏ទទួលបានវត្ថុអនុស្សាវរីយ៍បន្តិចបន្តួចពីសហគមន៍ផងដែរ ។ មនុស្សគ្រប់រូបនឹងច្រៀងចម្រៀងបទ ‘Advance Australia Fair’ ដែលជាភ្លេងជាតិប្រទេសអូស្ត្រាលី ។ បន្ទាប់ពីពិធីចូលសញ្ជាតិ លោកអ្នកនឹងមានឱកាសជួប និងអបអរសាទរជាមួយជនជាតិអូស្ត្រាលីឯទៀតដូចលោកអ្នកដែរ ។

យើងសូមជូនពរឱ្យលោកអ្នកទទួលបានជោគជ័យគ្រប់បែបយ៉ាងក្នុងការក្លាយជាពលរដ្ឋអូស្ត្រាលីមួយរូប ហើយនិងក្នុងការស្វែងរកជីវិតពោពេញទៅដោយសន្តិភាព និងវិបុលផលនៅក្នុងប្រទេសអូស្ត្រាលី ។

សម្រាប់ព័ត៌មានបន្ថែម

សូមចូលមើលវិបសាយថ៍ស្តីពីភាពជាលរដ្ឋអូស្ត្រាលីនៅ www.citizenship.gov.au ។

នៅដើម
ផ្នែកដែលអាចយកមកប្រឡង

ផ្នែកទី 1

ប្រទេសអូស្ត្រាលី និងជនជាតិរបស់ខ្លួន

ប្រទេសអូស្ត្រាលី និងជនជាតិរបស់ខ្លួន

នៅក្នុងពិធីចូលសញ្ជាតិ លោកអ្នកធ្វើសច្ចាប្រណិធាននូវភក្ដីភាពរបស់លោកអ្នកចំពោះប្រទេសអូស្ត្រាលី និងជនជាតិអូស្ត្រាលី ។ ដោយហេតុនេះ វាមានសារៈសំខាន់សម្រាប់លោកអ្នកដើម្បីស្វែងយល់ពីសហគមន៍ និងប្រជាជនអូស្ត្រាលី ដោយរាប់បញ្ចូលទាំងកេរដំណែលនៃជនជាតិដើមរបស់យើង ។ វាក៏ជាការសំខាន់ផងដែរសម្រាប់លោកអ្នកដើម្បីស្វែងយល់ពីប្រវត្តិសាស្ត្រប្រទេសអូស្ត្រាលី ហើយនិងថាតើយើងបានអភិវឌ្ឍទៅជាប្រជាជាតិពហុវប្បធម៌មួយប្រកបដោយជោគជ័យ និងស្ថេរភាពយ៉ាងដូចម្ដេច ។

នៅក្នុងផ្នែកនេះ លោកអ្នកនឹងអានអំពីព្រឹត្តិការណ៍ខ្លះដែលបានផ្ដល់វិភាគទានដល់ប្រវត្តិរបស់យើង ។ មានព័ត៌មានស្ដីពីរដ្ឋ និងដែនដីរបស់យើង ហើយនិងទំនៀមទម្លាប់ និងសញ្ញានានាដែលយើងស្គាល់អត្តសញ្ញាណប្រកបដោយមោទនភាពថាជារបស់ជនជាតិអូស្ត្រាលីពិតប្រាកដ ។

ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្រ្តេត (Torres Strait)

អ្នកស្រុកដំបូងរបស់អូស្ត្រាលីគឺជាជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្រ្តេត (Torres Strait) ដែលមានវប្បធម៌ និងទំនៀមទម្លាប់បន្តចាស់ជាងគេបង្អស់នៅក្នុងពិភពលោក ។

តាមប្រវត្តិសាស្ត្រជនជាតិដើមអាបូរីជីនីមកពីប្រទេសអូស្ត្រាលីដីគោក និងរដ្ឋតាស្មានីយ៉ា ។ កំណត់ត្រារបស់បុរាណវត្ថុវិទូបង្ហាញថាជនជាតិដើមអាបូរីជីនីបានមកដល់ប្រទេសអូស្ត្រាលីនៅចន្លោះ 65.000 និង40.000 ឆ្នាំកន្លងទៅ ក៏ប៉ុន្តែជនជាតិដើមអាបូរីជីនីមានជំនឿថាពួកគេជាអ្នកសំខាន់ជាងគេនៅក្នុងប្រវត្តិបង្កើតទឹកដីនេះ ហើយប្រវត្តិបង្កើតទឹកដីរបស់ពួកគេចាប់ផ្ដើមដោយមានការចាប់ផ្ដើមតាំងពីពេលមានការកកើតដំបូងមកម្លេះ ។ ជនជាតិដើមរស់នៅតាមកោះ Torres Strait មកពីកោះនៅចន្លោះចុងភាគខាងជើងនៃរដ្ឋឃ្វីនស្លែនដ៍ និងប្រទេសប៉ាពូញ៉ូវហ្គីណេ ។

ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្រ្តេត (Torres Strait) មានជំនឿ និងទំនៀមទម្លាប់ជាយូរលង់ដែលនៅតែនាំផ្លូវពួកគេរហូតដល់សព្វថ្ងៃនេះ ។ ពួកគេមានទំនាក់ទំនងយ៉ាងជ្រាលជ្រៅជាមួយទឹកដីដែលបានសម្ដែងនៅក្នុងរឿងនិទាន សិល្បៈ និងរបាំរបស់ពួកគេ ។ វប្បធម៌របស់ជនជាតិដើមមានភាពចម្រុះ ហើយជាផ្នែកដែលមានសារៈសំខាន់មួយនៃអត្តសញ្ញាណជាតិរបស់ប្រទេសអូស្ត្រាលី ។

ព័ត៌មានបន្ថែមស្ដីពីជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្រ្តេត (Torres Strait *អាចរកមើលបាននៅ ផ្នែកទី 5–ប្រទេសអូស្ត្រាលីនាពេលបច្ចុប្បន្ននិងផ្នែកទី 5–ប្រវត្តិនៃជនជាតិអូស្ត្រាលីរបស់យើង.*

ការតាំងលំនៅដ្ឋានរបស់ជនជាតិអឺរ៉ុបលើកដំបូង

ការតាំងលំនៅដ្ឋានរបស់ជនជាតិអឺរ៉ុបបានចាប់ផ្ដើមនៅពេលដែលសំពៅដឹកអ្នកទោសចំនួន 11 ដំបូងដែលគេស្គាល់ថាជា “កងនាវាទីមួយ” បានមកដល់ពីចក្រភពអង់គ្លេសនៅថ្ងៃទី 26ខែមករា ឆ្នាំ1788 ។

នៅពេលនោះ ច្បាប់ចក្រភពអង់គ្លេសមានលក្ខណៈឃោរឃៅណាស់ ហើយមន្ទីរឃុំឃាំងមិនអាចមានសមត្ថភាពដាក់មនុស្សដ៏ច្រើនដែលបានជាប់ពន្ធនាគារដោយសារបទឧក្រិដ្ឋរបស់ពួកគេបាន ។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលចក្រភពអង់គ្លេសបានសម្រេចដឹកជញ្ជូនអ្នកទោសទៅដាក់ឱ្យរស់នៅផ្នែកម្ខាងទៀតនៃពិភពលោក គឺតំបន់អាណានិគមថ្មីនៃរដ្ឋញ៉ូវសៅវែលស៍ ។

ទេសាភិបាលទីមួយនៃតំបន់អាណានិគមថ្មីនៃរដ្ឋញ៉ូវសៅវែលស៍គឺលោកនាយនាវាឈ្មោះ Arthur Phillip ។ តំបន់អាណានិគមនេះបានមានជីវិតគង់វង្ស ហើយដោយសារមានអ្នកទោស និងអ្នកតាំងលំនៅដ្ឋានដោយសេរីបានមកដល់កាន់តែច្រើន តំបន់អាណានិគមនេះបានលូតលាស់ និងអភិវឌ្ឍឡើង ។ តំបន់អាណានិគមជាច្រើនទៀតត្រូវបានបង្កើតឡើងនៅផ្នែកដទៃទៀតនៃប្រទេសអូស្ត្រាលី ។

អ្នកតាំងលំនៅដ្ឋានដោយសេរីដំបូងបានមកពីចក្រភពអង់គ្លេស និងប្រទេសអៀរឡង់ដ៍ ។ កេរដំណែលចក្រភពអង់គ្លេស និងអៀរឡង់បានមានឥទ្ធិពលដ៏ធំធេងមកលើប្រវត្តិសាស្ត្រ វប្បធម៌ និងនយោបាយក្នុងពេលថ្មីៗរបស់ប្រទេសអូស្ត្រាលី ។

នៅឆ្នាំ 1851 ‘ការសម្រុកទៅរកមាស’ បានចាប់ផ្ដើម នៅពេលគេបានរកឃើញមាសនៅក្នុងតំបន់អាណានិគមនានានៃរដ្ឋញ៉ូវសៅវែលស៍ និងវិចតូរីយ៉ា ។ មនុស្សនៅជុំវិញពិភពលោកបានមកកាន់តំបន់អាណានិគមទាំងនេះដើម្បីផ្សងសំណាងរកទ្រព្យសម្បត្តិ ។ ជនជាតិចិនដែលបានមកដល់ នៅពេលនោះគឺជាក្រុមជនចំណាកស្រុកយ៉ាងធំទីមួយដែលមិនមែនមកពីទ្វីបអឺរ៉ុប ។ ក្នុងរយៈពេល 10 ឆ្នាំ ចំនួនប្រជាជនប្រទេសអូស្ត្រាលីបានកើនឡើងច្រើនជាងពីរដង ។

ប្រជាជាតិអូស្ត្រាលី

នៅឆ្នាំ 1901 តំបន់អាណានិគមដែលនៅដាច់ៗពីគ្នាបានរួបរួមគ្នាជាសហព័ន្ធនៃរដ្ឋដែលគេហៅថាកុំម៉ន់វេលអូស្ត្រាលី (Commonwealth of Australia) ។ គឺនៅពេលនេះហើយ ដែលស្ថាប័នប្រជាធិបតេយ្យជាតិរបស់យើងដោយរួមមានសភាជាតិ រដ្ឋាភិបាល និងតុលាការជាន់ខ្ពស់ត្រូវបានបង្កើតឡើងនៅក្រោមរដ្ឋធម្មនុញ្ញអូស្ត្រាលីថ្មី ។នៅឆ្នាំ1901 ចំនួនប្រជាជននៃប្រទេសអូស្ត្រាលីមានចំនួនប្រមាណជាបួនលាននាក់ ។ ចំនួននេះមិនបានរាប់បញ្ចូលជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះ ថ័រិសស្រ្តេត (Torres Strait)ទេ ដោយសារគ្មានចំនួនជនជាតិដើមទេទើបដល់ពេល បន្ទាប់ពីការធ្វើប្រជាមតិនៅក្នុងឆ្នាំ 1967 ទើបពួកគេត្រូវបានរាប់បញ្ចូលនៅក្នុងការស្ទង់មើលចំនួនប្រជាជននៃប្រទេសអូស្ត្រាលី ។

ក្នុងរវាងពាក់កណ្តាលទីមួយនៃសតវត្សរ៍ទី20 កម្រិតនៃការធ្វើចំណាកស្រុកបានកើនឡើងនិងធ្លាក់ចុះវិញ ។ មានកម្មវិធីសម្រាប់លើកទឹកចិត្តយ៉ាងសកម្មដល់ជនចំណាកស្រុកចក្រភពអង់គ្លេសឱ្យមកតាំងលំដ្ឋាននៅទីនេះ ហើយមានមនុស្សជាច្រើនបានមកតាំងលំនៅដ្ឋាន ។

រលកនៃការធ្វើចំណាកស្រុកដែលមិនមែនជាជនជាតិចក្រភពអង់គ្លេសបានមកនៅក្រោយសង្គ្រាមលោកលើកទី II នៅពេលមនុស្សរាប់លាននាក់នៅទ្វីបអឺរ៉ុបបានត្រូវចាកចេញពីពីមាតុភូមិរបស់ពួកគេ ។ ចំនួនជនជាតិអឺរ៉ុបយ៉ាងច្រើនបានមកប្រទេសអូស្ត្រាលីដើម្បីកសាងជីវិតថ្មី ។

ក្នុងឆ្នាំថ្មីៗកន្លងមកនេះ កម្មវិធីជនចំណាកស្រុក និងជនភៀសខ្លួនបាននាំយកមនុស្សមកប្រទេសអូស្ត្រាលីពីពាសពេញពិភពលោក ។ មនុស្សបានមកទីនេះដើម្បីជួបជុំគ្រួសារ ដើម្បីកសាងជីវិតថ្មី ឬក៏ដើម្បីគេចចេញពីភាពក្រីក្រ សង្គ្រាម ឬក៏ការធ្វើទុក្ខបុកម្នេញ ។

ភាពចម្រុះនៃប្រជាជនអូស្ត្រាលីបានកើនឡើងក្នុងរយៈពេលពីរសតវត្សរ៍ចុងក្រោយនេះ ។ សង្គមរុងរឿង និងចម្រុះនេះបានធ្វើឱ្យប្រសើរឡើងនូវការផ្សារភ្ជាប់ប្រទេសអូស្ត្រាលីទៅនឹងពិភពលោក ។ ក្នុងខណៈដែលយើងអបអរសាទរភាពចម្រុះនៃប្រជាជនអូស្ត្រាលី យើងក៏មានគោលបំណងដើម្បីកសាងប្រជាជាតិមួយដែលផ្សារភ្ជាប់គ្នា និងរួបរួមគ្នាជាធ្លុងមួយ ។

ភាសាជាតិរបស់ប្រទេសអូស្ត្រាលីគឺភាសាអង់គ្លេស ។ វាជាផ្នែកមួយនៃអត្តសញ្ញាណជាតិរបស់យើង ។ ក្នុងការរក្សាគុណតម្លៃនៃប្រទេសអូស្ត្រាលីជនចំណាកស្រុកគួររៀន និងប្រើភាសាអង់គ្លេសដើម្បីជួយពួកគេឱ្យចូលរួមនៅក្នុងសង្គមអូស្ត្រាលី ។ ទំនាក់ទំនងជាភាសាអង់គ្លេសគឺមានសារៈសំខាន់ដើម្បីទទួលបានផលប្រយោជន៍ច្រើនបំផុត នៅក្នុងការរស់នៅ និងការធ្វើការងារក្នុងប្រទេសអូស្ត្រាលី ។

ភាសាដទៃទៀតក៏ត្រូវបានឱ្យតម្លៃផងដែរដោយរួមមានភាសាផ្សេងៗរបស់ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្រ្តេត (Torres Strait) ជាង 100 ភាសា ។

រដ្ឋ និងដែនដីនៃប្រទេសអូស្ត្រាលី

កុម៉ន់វេលអូស្ត្រាលី (Commonwealth of Australia) គឺជាសហព័ន្ធនៃរដ្ឋ និងដែនដី ។ មានរដ្ឋចំនួនប្រាំមួយ និងដែនដីចំនួនពីរ ។ ក្រុងកង់បេរ៉ាគឺជារាជធានីនៃប្រទេសអូស្ត្រាលី ហើយរដ្ឋ និងដែនដីគោគនីមួយៗមានរាជធានីរបស់ខ្លួន ។



រដ្ឋ	រាជធានី
New South Wales (NSW)	Sydney
Victoria (Vic.)	Melbourne
Queensland (Qld)	Brisbane
Western Australia (WA)	Perth
South Australia (SA)	Adelaide
Tasmania (Tas.)	Hobart
Territory	**Capital city**
Australian Capital Territory (ACT)	Canberra
Northern Territory (NT)	Darwin

រដ្ឋ

ញ៉ូវសៅវែលស៍ (New South Wales) គឺជាតំបន់អាណានិគមទីមួយដែលបានបង្កើតឡើងដោយជនជាតិចក្រភពអង់គ្លេស ។ ក្រុងស៊ីដនី (Sydney) គឺជារាជធានីនៃរដ្ឋញ៉ូវសៅវែលស៍ ហើយជាទីក្រុងធំជាងគេបង្អស់របស់ប្រជាជាតិ ។ ស្ពាន Sydney Harbour និងរោងល្ខោនអូប៉េរ៉ានៃក្រុងស៊ីដនី (Sydney Opera House) គឺជារូបតំណាងល្បីល្បាញ ។



វិចតូរីយ៉ា (Victoria) គឺជារដ្ឋដីគោកដែលតូចជាងគេបង្អស់ ។ រាជធានីនៃរដ្ឋវិចតូរីយ៉ាគឺទីក្រុងម៉ែលប៊ន (Melbourne) ។ អគារស្អាតៗជាច្រើននៅរដ្ឋវិចតូរីយ៉ាបានកសាងឡើងពីទ្រព្យសម្បត្តិបានមកដោយសារការសម្រុកទៅរកមាសក្នុងទសវត្សរ៍ឆ្នាំ 1850 ។ រូបតំណាងល្បីល្បាញនៃរដ្ឋវិចតូរីយ៉ារាប់បញ្ចូលទីធ្លាលេងកីឡាគ្រីឃីត (Melbourne Cricket Ground) សសរថ្មទាំង 12 (12 Apostles) ហើយនិងរាជអគារតាំងពិព័រណ៍ (the Royal Exhibition Building) ។



ឃ្វីនស្លែនដ៍ (Queensland) គឺរដ្ឋធំជាងគេទីពីរ ។ រាជធានីនៃរដ្ឋឃ្វីនស្លែនដ៍គឺទីក្រុងព្រីសបេន (Brisbane) ។ កោះ Torres Strait ស្ថិតនៅភាគខាងជើងនៃរដ្ឋ ហើយជួរថ្មប៉ប្រះទឹកដែលមានផ្កាថ្មដ៏ធំល្វឹងល្វើយ (Great Barrier Reef) ដែលល្បីល្បាញទូទាំងពិភពលោកលាតសន្ធឹងនៅតាមឆ្នេរសមុទ្រខាងកើតរបស់ខ្លួន ។ ឃ្វីនស្លែនដ៍មានព្រៃទឹកភ្លៀងតំបន់ត្រូពិច តំបន់ឆ្នេរសមុទ្រដែលមានសីតុណ្ហភាពមធ្យម ហើយនិងដីនៅឆ្ងាយពីសមុទ្រស្ងួតជាញឹកញាប់ ។



អូស្ត្រាលីខាងលិច (Western Australia) គឺជារដ្ឋធំជាងគេបំផុត ។ ភើត (Perth) គឺជារាជធានីនៃរដ្ឋអូស្ត្រាលីភាគខាងលិច ។ តំបន់ខាងកើតនៃរដ្ឋភាគច្រើនជាវាលខ្សាច់ រីឯតំបន់និរតីសម្បូរទៅដោយតំបន់កសិកម្ម និងដាំទំពាំងបាយជូរធ្វើស្រា ។ រដ្ឋនេះជាលំនៅដ្ឋានសម្រាប់គម្រោងជីកយកធនធានរ៉ែធំៗជាច្រើន ។ រូបតំណាងល្បីល្បាញនៃរដ្ឋអូស្ត្រាលីខាងលិចរួមមានឆ្នេរសមុទ្រ Ningaloo Coast ទន្លេ Margaret River ហើយនិងតំបន់ទេសភាព Kimberley ។



អូស្ត្រាលីខាងត្បូង (South Australia) មានឆ្នេរច្រាំងសមុទ្រដែលមានផ្ទាំងថ្មធំៗ និងតំបន់ផលិតស្រាទំពាំងបាយជូរដ៏ល្បីល្បាញជាច្រើន ។ ក្រុងអាដឺឡែត (Adelaide) ដែលជារាជធានីមានគំរូស្ថាបត្យកម្មអាណានិគមស្អាតៗ ជាច្រើន ។ រូបតំណាងល្បីល្បាញនៃរដ្ឋអូស្ត្រាលីខាងត្បូងរួមមានជ្រលងភ្នំ Barossa Valley និងជួរភ្នំ Flinders Ranges ។

តាស្មានីយ៉ា (Tasmania) គឺជារដ្ឋដែលតូចជាងគេបំផុតដែលនៅដាច់ពីដីគោកដោយច្រកសមុទ្រ Bass Strait ។ រាជធានីនៃរដ្ឋតាស្មានីយ៉ាគឺក្រុងហូបាត (Hobart) ។ កន្លែងភាគច្រើននៅលើកោះមានទេសភាពព្រៃរហោឋានធម្មជាតិដ៏ស្រស់បំព្រង ។ រូបតំណាងល្បីល្បាញនៃរដ្ឋតាស្មានីយ៉ារួមមានភ្នំ Cradle Mountain កំពង់ផែ Port Arthur និងឆកសមុទ្រ Bay of Fires ។



ដែនដី

ដែនដីរាជធានីអូស្ត្រាលី (Australian Capital Territory) ស្ថិតនៅចន្លោះទីក្រុង ស៊ីដនី និងទីក្រុងម៉ែលប៊ន ។ វាជាលំនៅដ្ឋានសម្រាប់រាជធានីរបស់ប្រជាជាតិឈ្មោះកង់បេរ៉ា (Canberra) ។ ស្ថាប័នជាតិមួយចំនួនមានទីតាំងនៅរាជធានីកង់បេរ៉ា ដោយរាប់បញ្ចូលទាំងមន្ទីររដ្ឋសភា និងតុលាការជាន់ខ្ពស់នៃប្រទេសអូស្ត្រាលី ។



ដែនដីខាងជើង (Northern Territory) មានបរិស្ថានតំបន់ត្រូពិច នៅខាងជើងនៃរដ្ឋ និង វាលខ្សាច់ពណ៌ក្រហមស្ងួតនៅខាងត្បូង ។ ដាវីន (Darwin) គឺជារាជធានី ។ រូបតំណាងល្បីល្បាញនៃដែនដីខាងជើងរួមមានភ្នំ Uluru ភ្នំ Kata Tjuta និង ភ្នំ Kings Canyon ។



ប្រពៃណី

ពិធីការស្វាគមន៍ភ្ញៀវចូលស្រុក និងពិធីការសម្ដែងការគោរពដឹងគុណដល់ម្ចាស់ស្រុក

ពិធីស្វាគមន៍ពលរដ្ឋថ្មីចូលប្រទេសគឺជាពិធីវប្បធម៌មួយដែលសម្ដែងដោយជនជាតិដើមអាបូរីជីនី ឬក៏អាណាព្យាបាលរបស់ជនជាតិដើមរស់នៅតាមកោះថ័ររិសស្រ្តែត (Torres Strait) នៅក្នុងតំបន់ដែលស្វាគមន៍ភ្ញៀវមកកាន់ទឹកដីប្រពៃណីរបស់ពួកគេ ។ តាមប្រពៃណី ពិធីនេះត្រូវសម្ដែងឡើងដើម្បីធានាថាភ្ញៀវធ្វើដំណើរប្រកបដោយសុវត្ថិភាព និងទទួលបានការការពារនៅអំឡុងពេលដែលពួកគេនៅលើទឹកដីនោះ ។

ពិធីស្វាគមន៍ភ្ញៀវចូលស្រុកអាចប្រារព្ធឡើងតាមរបៀបផ្សេងៗជាច្រើនដោយរាប់បញ្ចូលទាំងចម្រៀង របាំ ពិធីដុតស្លឹកឈើ (smoking ceremonies) ឬក៏សុន្ទរកថាជាភាសាប្រពៃណី ឬជាភាសាអង់គ្លេស ។

ពិធីស្វាគមន៍ភ្ញៀវចូលស្រុកគឺជារបៀបវារៈទីមួយនៅក្នុងដំណើរការនៃពិធីនេះដើម្បីបើកពិធីមួយ ។

ពិធីសម្ដែងការគោរពដឹងគុណដល់ម្ចាស់ស្រុកគឺជាឱកាសមួយ ដើម្បីទទួលស្គាល់ថាការជួបជុំនេះគឺនៅលើទឹកដីរបស់ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័ររិសស្រ្តែត (Torres Strait) ដើម្បីគោរពដល់អាណាព្យាបាលតាមប្រពៃណី ជាពិសេសចាស់ទុំនៅអតីតកាល និងបច្ចុប្បន្នកាល ហើយនិងសម្ដែងការគោរព ដឹងគុណដល់ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័ររិសស្រ្តែត (Torres Strait) ដែលបានចូលរួមក្នុងពិធីនេះ ។

ពិធីសម្ដែងការគោរពដឹងគុណដល់ម្ចាស់ស្រុកគឺប្រារព្ធឡើងជាផ្នែកមួយនៃពិធីស្វាគមន៍ និងការរៀបចំចាត់ចែងនៅក្នុងកិច្ចប្រជុំ និងក្នុងពិធីនានា ។ អ្នកណាក៏អាចធ្វើពិធីសម្ដែងការគោរពដឹងគុណដល់ម្ចាស់ស្រុកបានដែរ ។ នៅក្នុងកិច្ចប្រជុំ និងក្នុងពិធីនានា ជាទូទៅពិធីនេះអាចធ្វើដោយប្រធាន ឬក៏អ្នកគ្រប់គ្រងពិធី ។

ពិធីប្រពៃណីទាំងនេះត្រូវសម្ដែងឡើងដើម្បីបង្ហាញការគោរពចំពោះជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័ររិសស្រ្តែត (Torres Strait) ។

ថ្ងៃសំខាន់ៗសម្រាប់ជនជាតិអូស្ត្រាលី

ទិវាបុណ្យជាតិអូស្ត្រាលី (Australia Day)

នៅថ្ងៃទី 26 ខែមករាជារៀងរាល់ឆ្នាំ យើងធ្វើពិធីបុណ្យអបអរសាទរទិវាបុណ្យជាតិអូស្ត្រាលី។ ទិវាបុណ្យជាតិអូស្ត្រាលីគឺជាថ្ងៃឈប់សម្រាកសាធារណៈនៅគ្រប់រដ្ឋ និងដែនដីនៅក្នុងប្រទេសអូស្ត្រាលី។ ថ្ងៃនេះគឺជាថ្ងៃខួបនៃការមកដល់នៃកងនាវាទីមួយពីចក្រភពអង់គ្លេសនៅឆ្នាំ 1788។

នៅថ្ងៃបុណ្យជាតិអូស្ត្រាលី សហគមន៍នានានៅទូទាំងប្រទេសអូស្ត្រាលីឆ្លុះបញ្ចាំងទៅលើប្រវត្តិសាស្ត្ររបស់យើង ហើយនិងមនុស្សដែលបានចូលរួមវិភាគទានដល់សមិទ្ធិផលរួមរបស់យើង។ ថ្ងៃនេះគឺថ្ងៃឈប់សម្រាកសាធារណៈប្រចាំឆ្នាំធំជាងគេបង្អស់នៅប្រទេសអូស្ត្រាលី។

ថ្ងៃបុណ្យជាតិអូស្ត្រាលីគឺនិយាយអំពីការដឹងគុណ និងអបអរសាទរដល់វិភាគទានដែលជនជាតិអូស្ត្រាលីគ្រប់រូបបានធ្វើចំពោះប្រជាជាតិសម័យបច្ចុប្បន្ន និងដ៏ស្វាហាប់របស់យើង ៖ ពីជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្រ្តេត (Torres Strait) - ដែលបានរស់នៅទីនេះអស់រយៈពេលប្រមាណជា 65.000ឆ្នាំហើយ - មកដល់អ្នកដែលបានរស់នៅទីនេះរាប់ជំនាន់ និងអ្នកដែលបានមកទីនេះពីគ្រប់ទិសទី នៅក្នុងពិភពលោកហើយចាត់ទុកប្រទេសយើងជាស្រុកកំណើត។ ទិវាបុណ្យជាតិអូស្ត្រាលីត្រូវបានប្រារព្ធឡើងដោយមានពិធីផ្សេងៗនៅទូទាំងប្រទេសអូស្ត្រាលីដោយរួមមានពិធីចូលសញ្ជាតិពិសេសនានា។

នៅអំឡុងពេលអបអរសាទរដល់ថ្ងៃបុណ្យជាតិអូស្ត្រាលី នាយករដ្ឋមន្ត្រីប្រកាសឈ្មោះជនជាតិអូស្ត្រាលីឆ្នើមទទួលពានរង្វាន់ប្រចាំឆ្នាំ នៅរាជធានីកង់បេរ៉ា។

ទិវាបុណ្យជាតិ Anzac Day

ទិវាបុណ្យជាតិ Anzac Day គឺត្រូវប្រារព្ធធ្វើនៅថ្ងៃទី25ខែមេសាជារៀងរាល់ឆ្នាំ។ ទិវាបុណ្យជាតិ Anzac Day ត្រូវបានគេដាក់ឈ្មោះ តាមអង្គភាពកងទ័ពអូស្ត្រាលី និងណូវ៉ែលហ្សេឡង់ដែលបានចុះពីនាវាឡើងគោកនៅឯឧបទ្វីប Gallipoli នៅសាធារណរដ្ឋទួរគីនៅសង្គ្រាមលោកលើកទីមួយ នៅថ្ងៃ ទី25 ខែមេសា ឆ្នាំ 1915។

ទិវាបុណ្យជាតិ Anzac Day គឺជាថ្ងៃដ៏ឱឡារិកមួយដែលយើងចងចាំការបូជាជីវិតរបស់ជនជាតិអូស្ត្រាលីទាំងអស់ដែលបានចូលបម្រើទ័ព និងស្លាប់នៅក្នុងសង្គ្រាមជម្លោះ និងប្រតិបត្តិការរក្សាសន្តិភាពនានា។ យើងក៏ផ្តល់កិត្តិយសចំពោះសេចក្តីក្លាហាន និងការប្តេជ្ញារបស់កងប្រដាប់អាវុធបុរសនិងស្ត្រីទាំងអស់ផងដែរ ហើយនិងឆ្លុះបញ្ចាំងទៅលើអត្ថន័យខុសៗគ្នាជាច្រើននៃសង្គ្រាម។

ព័ត៌មានស្តីពីទិវាបុណ្យជាតិ និងពិធីអបអរសាទរសំខាន់ៗផ្សេងទៀតអាចមើលនៅផ្នែកទី 5 ស្តីពីប្រទេសអូស្ត្រាលីក្នុងពេលបច្ចុប្បន្ននេះ។

ទង់ជាតិនៃប្រទេសអូស្ត្រាលី

ទង់ជាតិប្រទេសអូស្ត្រាលីគឺជាទង់ជាតិផ្លូវការរបស់ប្រជាជាតិយើង ។ ទង់ជាតិផ្សេងៗទៀតដែលបានទទួលស្គាល់ជាផ្លូវការ ហើយអាចបង្ហោះនៅក្នុងសហគមន៍ រាប់បញ្ចូលទាំងទង់ជាតិជនជាតិដើមអាបូរីជីនីអូស្ត្រាលី និងទង់ជាតិជនជាតិដើមរស់នៅតាមកោះច់វ៉រិសស្រ្តេត (Torres Strait) អូស្ត្រាលី ។

រដ្ឋ និងដែនដីនីមួយៗក៏មានទង់ជាតិផ្ទាល់ខ្លួនរបស់ពួកគេដែរ ដែលអាចរកឃើញនៅទំព័រទី11 ។

ទង់ជាតិអូស្ត្រាលី

ទង់ជាតិអូស្ត្រាលីមានពណ៌ខៀវ ស និងក្រហម ។

- ‘Union Jack’ ដែលជាទង់ជាតិរបស់ចក្រភពអង់គ្លេសស្ថិតនៅជ្រុងឆ្វេងខាងលើ ។ វាតំណាងឱ្យប្រវត្តិនៃការតាំងលំនៅដ្ឋានរបស់ចក្រភពអង់គ្លេសរបស់យើង ហើយនិងច្បាប់ និងស្ថាប័នដែលយើងបានទទួលមរកតពីចក្រភពអង់គ្លេស ។
- ផ្កាយកុំម៉ន់វែលនៅខាងក្រោម Union Jack ។ ផ្កាយនេះមានជ្រុងចំនួនប្រាំពីរ ដោយជ្រុងនីមួយៗតំណាងឱ្យរដ្ឋទាំងប្រាំមួយ និងជ្រុងមួយតំណាងឱ្យដែនដី ។
- Southern Cross ដែលនៅខាងស្តាំគឺជាក្រុមផ្កាយដែលយើងអាចមើលឃើញនៅលើផ្ទៃមេឃខាងត្បូង ។

ទង់ជាតិជនជាតិដើមអាបូរីជីនីអូស្ត្រាលី

ទង់ជាតិជនជាតិដើមអាបូរីជីនីអូស្ត្រាលីមានពណ៌ខ្មៅ ក្រហម និងលឿង ។

- ផ្នែកពាក់កណ្តាលខាងលើមានពណ៌ខ្មៅ និងតំណាងឱ្យជនជាតិដើមអាបូរីជីនីនៃប្រទេសអូស្ត្រាលី ។
- ផ្នែកពាក់កណ្តាលខាងក្រោមមានពណ៌ក្រហម និងតំណាងឱ្យផែនដីដែលមានសារៈសំខាន់នៅក្នុងពិធី ។
- រង្វង់ពណ៌លឿងតំណាងឱ្យព្រះអាទិត្យ ។

ទង់ជាតិជនជាតិដើមរស់នៅតាមកោះច់វ៉រិសស្រ្តេត (Torres Strait)

ទង់ជាតិជនជាតិដើមរស់នៅតាមកោះច់វ៉រិសស្រ្តេត (Torres Strait) មានពណ៌បៃតង ខៀវ ខ្មៅ និងស ។

- ឆ្នូតពណ៌បៃតងតំណាងឱ្យទឹកដី ។
- បន្ទះពណ៌ខៀវនៅកណ្តាលតំណាងឱ្យសមុទ្រ ។
- ខ្សែគំនូសពណ៌ខ្មៅតំណាងឱ្យ ជនជាតិដើមរស់នៅតាមកោះច់វ៉រិសស្រ្តេត (Torres Strait) ។
- គ្រឿងពាក់នៅលើក្បាលអ្នករបាំពណ៌សនៅចំកណ្តាលគឺជានិមិត្តរូបសម្រាប់ជនជាតិដើមរស់នៅតាមកោះច់វ៉រិសស្រ្តេត (Torres Strait) ទាំងអស់គ្នា ។
- ជ្រុងរបស់ផ្កាយពណ៌សតំណាងឱ្យប្រជុំកោះនៅច់វ៉រិសស្រ្តេត (Torres Strait) ហើយពណ៌សជានិមិត្តរូបនៃសន្តិភាព ។



សញ្ញារបស់ប្រទេសអូស្ត្រាលី

សញ្ញាជាតិកុំម៉ន់វេល (Commonwealth Coat of Arms)

សញ្ញាជាតិកុំម៉ន់វេលគឺជាសញ្ញាផ្លូវការនៃកុំម៉ន់វេលអូស្ត្រាលី ។ វាតំណាងឱ្យឯកភាពជាតិរបស់យើង ។ វាជាអត្តសញ្ញាណនៃអាជ្ញាធរ និងកម្មសិទ្ធិនៃកុំម៉ន់វេលអូស្ត្រាលី (Commonwealth of Australia) ។

- ខែលនៅចំកណ្ដាលតំណាងឱ្យរដ្ឋទាំងប្រាំមួយ និងសហព័ន្ធ ។
- សត្វកង់ហ្គារូ (kangaroo) និងសត្វអ៊ីមញូ (emu) ទ្រខែលម្ខាងមួយ ។ សត្វទាំងពីរគឺជាសត្វមានដើមកំណើតនៅប្រទេសអូស្ត្រាលី ។
- ផ្កាយកុំម៉ន់វេលមាសស្ថិតនៅពីលើខែល ។
- ផ្ទៃខាងក្រោយគឺជាផ្កាវ៉ាតថលពណ៌មាស (golden wattle) ដែលជាផ្កាតំណាងជាតិរបស់ប្រទេសអូស្ត្រាលី ។

ផ្កាតំណាងជាតិរបស់ប្រទេសអូស្ត្រាលី

ផ្កាតំណាងជាតិរបស់ប្រទេសអូស្ត្រាលីគឺជាផ្កាវ៉ាតថលពណ៌មាស (golden wattle) ។ ដើមឈើតូចនេះច្រើនដុះនៅប៉ែកអាគ្នេយ៍នៃប្រទេសអូស្ត្រាលី ។ វាមានស្លឹកពណ៌បៃតងភ្លឺ និងផ្កាពណ៌លឿងដូចមាសជាច្រើននៅរដូវផ្ការីក ។ រដ្ឋ និងដែនដីនីមួយៗនៃប្រទេសអូស្ត្រាលីក៏មាននិមិត្តសញ្ញាផ្ការបស់ខ្លួនដែរ ។

ពណ៌តំណាងជាតិរបស់ប្រទេសអូស្ត្រាលី

ពណ៌តំណាងជាតិរបស់ប្រទេសអូស្ត្រាលីគឺពណ៌បៃតង និងមាស ដែលជាពណ៌នៃផ្កាវ៉ាតថលពណ៌មាស (golden wattle) ។ ជាធម្មតា ឯកសណ្ឋាននៃក្រុមកីឡាជាតិរបស់យើងមានពណ៌បៃតង និងពណ៌មាស ។



ត្បូងជាតិនៃប្រទេសអូស្ត្រាលី

ត្បូងអូផល (opal) គឺជាត្បូងជាតិនៃប្រទេសអូស្ត្រាលី ។ ដោយយោងទៅតាមរឿងព្រេងបូរាណរបស់ជនជាតិដើមអាបូរីជីនី មានឥន្ទធនូបានប៉ះនឹងផែនដី ហើយបានបង្កើតជាពណ៌នៃត្បូងអូផលនេះឡើង ។

ភ្លេងជាតិនៃប្រទេសអូស្ត្រាលី

‘Advance Australia Fair’ គឺជាភ្លេងជាតិនៃប្រទេសអូស្ត្រាលី ។ ភ្លេងជាតិនេះត្រូវបានគេច្រៀងនៅក្នុងឱកាសដែលមានព្រឹត្តិការណ៍ជាតិសំខាន់ៗ រួមមាន ដូចជាពិធីចូលសញ្ជាតិ និងព្រឹត្តិការណ៍កីឡាធំៗ ។

Advance Australia Fair

Australians all let us rejoice,
For we are one and free;
We’ve golden soil and wealth for toil;
Our home is girt by sea;
Our land abounds in nature’s gifts
Of beauty rich and rare;
In history’s page, let every stage
Advance Australia Fair.
In joyful strains then let us sing,
Advance Australia Fair.

Beneath our radiant Southern Cross
We’ll toil with hearts and hands;
To make this Commonwealth of ours
Renowned of all the lands;
For those who’ve come across the seas
We’ve boundless plains to share;
With courage let us all combine
To Advance Australia Fair.
In joyful strains then let us sing,
Advance Australia Fair.

ផ្នែកទីពីរ

ជំនឿលើលទ្ធិប្រជាធិបតេយ្យ សិទ្ធិ និងសេរីភាពនៃប្រទេសអូស្ត្រាលី

ជំនឿលើលទ្ធិប្រជាធិបតេយ្យ សិទ្ធិ និងសេរីភាពនៃប្រទេសអូស្ត្រាលី

នៅក្នុងពិធីចូលសញ្ជាតិ លោកអ្នកនឹងធ្វើសច្ចាប្រណិធានថាលោកអ្នកនឹងចែករំលែកជំនឿលើលទ្ធិប្រជាធិបតេយ្យរបស់ប្រទេសអូស្ត្រាលី និងគោរពសិទ្ធិ និងសេរីភាព ។ វាមានសារៈសំខាន់ណាស់សម្រាប់លោកអ្នកដើម្បីយល់ពីជំនឿលើលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិ ហើយនិងសេរីភាពដែលចែករំលែកដោយជនជាតិអូស្ត្រាលី ។

ផ្នែកនេះនៅក្នុងសៀវភៅមានរាយជំនឿ សិទ្ធិ និងសេរីភាពទាំងនេះ ។ សម្រាប់ព័ណ៌មានបន្ថែម សូមមើល*ផ្នែកទី4 ស្ដីពីគុណតម្លៃរបស់ប្រទេសអូស្ត្រាលី* ។

ជំនឿលើលទ្ធិប្រជាធិបតេយ្យរបស់យើង

លិទ្ធិប្រជាធិបតេយ្យតាមរយៈសភា

ប្រព័ន្ធរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីគឺលិទ្ធិប្រជាធិបតេយ្យតាមរយៈសភា ។ ជាផ្នែកមួយនៃប្រព័ន្ធនេះ អំណាចនៃរដ្ឋាភិបាលបានមកពីប្រជាជនអូស្ត្រាលី ពីព្រោះពលរដ្ឋអូស្ត្រាលីបោះឆ្នោតឱ្យមនុស្សធ្វើជាតំណាងរបស់ពួកគេនៅក្នុងសភា ។ តំណាងនៅក្នុងសភាត្រូវឆ្លើយតបទៅប្រជាជន តាមរយៈការបោះឆ្នោតសម្រាប់ការសម្រេចចិត្តដែលពួកគេធ្វើ ។

នីតិរដ្ឋ

ជនជាតិអូស្ត្រាលីទាំងអស់មានភាពស្មើគ្នានៅក្រោមច្បាប់ ។ នីតិរដ្ឋមានន័យថាគ្មាននរណាម្នាក់ ក្រុម ឬក៏បទបញ្ញត្តិសាសនាណាមួយនៅលើច្បាប់ទេ ។ មនុស្សគ្រប់រូបដោយរាប់បញ្ចូលទាំងមនុស្សដែលមានឋានៈអំណាចនៅក្នុងសហគមន៍អូស្ត្រាលីត្រូវតែគោរពច្បាប់ប្រទេសអូស្ត្រាលី ។ នេះរាប់បញ្ចូលទាំងរដ្ឋាភិបាល អ្នកដឹកនាំសហគមន៍ និងសាសនា ក៏ដូចជាអ្នកជំនួញ និងភ្នាក់ងារប៉ូលីសដែរ ។

ការរស់នៅដោយមានសន្តិភាពពេញលេញ

ជនជាតិអូស្ត្រាលីមានមោទនភាពដែលបានរស់នៅក្នុងប្រទេសមានសន្តិភាពពេញលេញ ដោយមានប្រព័ន្ធរដ្ឋាភិបាលស្ថេរភាពមួយ ។ ជនជាតិអូស្ត្រាលីជឿជាក់ថាការផ្លាស់ប្តូរគួរកើតឡើងតាមរយៈការពិភាក្សាគ្នា ការបញ្ចុះបញ្ចូលដោយសន្តិវិធី និងតាមរយៈដំណើរការប្រជាធិបតេយ្យ ។ យើងបដិសេធនូវអំពើហឹង្សាដែលជាវិធីមួយដើម្បីកែប្រែចិត្តគំនិតរបស់មនុស្សម្នាក់ ឬក៏ច្បាប់ ។

ការគោរពចំពោះបុគ្គលទាំងអស់ដោយមិនគិតពីសាវតារ

ប្រព័ន្ធប្រជាធិបតេយ្យរបស់ប្រទេសអូស្ត្រាលីគឺផ្អែកទៅលើគោលការណ៍ដែលបុគ្គលគ្រប់រូប ដោយមិនគិតពីប្រវត្តិរបស់ពួកគេ មានសិទ្ធិ និងសមភាពនៅក្រោមច្បាប់អូស្ត្រាលី ។ ជនជាតិអូស្ត្រាលីទាំងអស់ត្រូវប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយភាពថ្លៃថ្នូរ និងការគោរព ដោយមិនគិតពីពីពូជសាន៍ ប្រទេសដើមកំណើត ភេទ ការតម្រង់ទិសផ្លូវភេទ ស្ថានភាពគ្រួសារ អាយុ ពិការភាព មរតក វប្បធម៌ នយោបាយ ទ្រព្យសម្បត្តិ ឬសាសនា ឡើយ ។

សេរីភាពរបស់យើង

សេរីភាពក្នុងការនិយាយស្តី និងសេរីភាពក្នុងការសម្តែងមតិ

សេរីភាពខាងការនិយាយស្តីគឺជាគុណតម្លៃដ៏សំខាន់មួយរបស់ប្រទេសអូ អូស្ត្រាលី ហើយនិងគាំទ្រប្រព័ន្ធប្រជាធិបតេយ្យរបស់យើង ។ ឧទាហរណ៍ មនុស្សអាចទិតៀនរដ្ឋាភិបាល តវ៉ាប្រឆាំងសេចក្តីសម្រេចរបស់រដ្ឋាភិបាល ដោយសន្តិវិធី ហើយនិងធ្វើយុទ្ធនាការដើម្បីកែប្រែច្បាប់ ឱ្យតែពួកគេនៅគោរព ច្បាប់ប្រទេសអូស្ត្រាលីគ្រប់ពេល ។

សេរីភាពក្នុងការសម្តែងមតិមានន័យថាមនុស្សអាចបញ្ចេញទស្សនៈ របស់ពួកគេដោយរាប់បញ្ចូលទាំងតាមរយៈសិល្បៈ ខ្សែភាពយន្ត តន្ត្រី និងអក្សរសិល្ប៍ ។ មនុស្សមានសេរីភាពក្នុងការជួបជុំគ្នានៅទីកន្លែងសាធារណៈ ឬក៏ឯកជនដើម្បីពិភាក្សាអំពីនយោបាយ និងសង្គម ។

ច្បាប់នៃប្រទេសអូស្ត្រាលីត្រូវតែគោរពគ្រប់ពេល ទោះជានៅពេលចូលរួម ប្រើប្រាស់សេរីភាពក្នុងការនិយាយស្តី និងសេរីភាពក្នុងការបញ្ចេញមតិ ក៏ដោយ ។ យើងក៏ត្រូវតែគោរពសេរីភាពក្នុងការនិយាយស្តី និងសេរីភាពក្នុង ការបញ្ចេញមតិរបស់អ្នកដទៃដែរ ។

សេរីភាពក្នុងការបង្កើតសមាគម

សេរីភាពក្នុងការបង្កើតសមាគមគឺជាសិទ្ធិបង្កើត និងចូលរួមសមាគមដើម្បី ស្វែងរកគោលដៅរួម ។ ឧទាហរណ៍ នៅប្រទេសអូស្ត្រាលីមនុស្សមានសេរីភាព ដើម្បីចូលរួមក្នុងអង្គការស្របច្បាប់ណាមួយក៏បាន ដូចជាបក្សនយោបាយ សហជីព ក្រុមសាសនា វប្បធម៌ ឬក៏សង្គម ។ មនុស្សក៏អាចសម្រេចចិត្តមិន ចូលរួមដែរ ហើយមិនអាចត្រូវបានបង្ខំឱ្យធ្វើដូច្នេះទេ ។

ជនជាតិអូស្ត្រាលីអាចជួបជុំជាមួយអ្នកដទៃទៀតដើម្បីតវ៉ាប្រឆាំងសកម្មភាពរដ្ឋាភិបាល ឬក៏អង្គការបាន ។ ទោះជាយ៉ាងណាក្តី ច្បាប់នៃប្រទេសអូស្ត្រាលី ត្រូវតែគោរពគ្រប់ពេល ។ នេះមានន័យថាការជួបជុំរបៀបនេះត្រូវធ្វើទៅ ដោយសន្តិវិធី និងមិនត្រូវបង្ករបួសដល់ជនណាម្នាក់ ឬក៏ការខូតខាតដល់ ទ្រព្យសម្បត្តិណាមួយទេ ។

សេរីភាពខាងជំនឿសាសនា

ប្រទេសអូស្ត្រាលីទទួលកេរតំណែលសាសនាគ្រីស្ត-យូដា ហើយជនជាតិអូស្ត្រាលី ជាច្រើនចាត់ទុកថាពួកគេជាអ្នកកាន់សាសនាគ្រីស្ត ប៉ុន្តែមានប្រជាជននៅក្នុង ប្រទេសអូស្ត្រាលីមកពីសាសនាធំៗទាំងអស់ ។ ប្រទេសអូស្ត្រាលីមានការឈប់ សម្រាកសាធារណៈនៅទិវាបុណ្យសាសនាគ្រីស្ត ដូចជាថ្ងៃបុណ្យព្រះយេស៊ូសុគត ថ្ងៃបុណ្យព្រះយេស៊ូរស់ឡើងវិញ និងថ្ងៃបុណ្យណូអែល ។

រដ្ឋាភិបាល និងច្បាប់ចាត់ទុកពលរដ្ឋទាំងអស់ស្មើភាពគ្នា មិនថាពួកគេមាន ជំនឿ ឬក៏សាសនាអ្វីទេ ។ រដ្ឋាភិបាលអូស្ត្រាលីគឺមិនពាក់ព័ន្ធនឹងសាសនាទេ ដែលមានន័យថារដ្ឋាភិបាលប្រព្រឹត្តទៅ ដាច់ដោយឡែកពីវិហា ឬក៏ក្រុមសាសនាផ្សេងៗទៀត ។ ប្រជាជននៅក្នុងប្រទេសអូស្ត្រាលីមានសេរីភាពកាន់សាសនាណាមួយដែលពួកគេបាន ជ្រើសរើស ។ ពួកគេក៏អាចជ្រើសរើសមិនកាន់សាសនាបានដែរ ។

ច្បាប់នៃប្រទេសអូស្ត្រាលីត្រូវតែគោរពគ្រប់ពេល ទោះជានៅពេលចូលរួមក្នុង ការប្រតិបត្តិខាងផ្លូវសាសនាក៏ដោយ ។ ក្នុងខណៈដែលមានជម្លោះរវាង ច្បាប់ប្រទេសអូស្ត្រាលី និងការប្រតិបត្តិផ្នែកសាសនា ច្បាប់អូស្ត្រាលីមាន ប្រៀបលើ ។

សមភាពរបស់យើង

នៅក្នុងប្រទេសអូស្ត្រាលីមានច្បាប់មួយចំនួនដែលធានាថាគ្មានជនណាម្នាក់ត្រូវបានគេចាត់ទុកខុសពីអ្នកដទៃទៀតទេ ដោយសារភេទ ជាតិសាសន៍ ពិការភាព ឬក៏អាយុរបស់ពួកគេ ។

សមភាពយេនឌ័រ

បុរស និងស្ត្រីមានសិទ្ធិស្មើគ្នានៅប្រទេសអូស្ត្រាលី ។ ការរើសអើងប្រឆាំងនឹងមនុស្សម្នាក់ ដោយសារភេទរបស់ពួកគេគឺជាការប្រឆាំងនឹងច្បាប់ ។

សមភាពនៃឱកាស ហើយនិង ‘ឱកាសដូចគ្នា’ (fair go)

ជនជាតិអូស្ត្រាលីឱ្យតម្លៃទៅលើឱកាសស្មើគ្នានៅក្នុងសង្គមរបស់យើង អ្វីដែលជាញឹកញាប់គេហៅថា ‘ឱកាសដូចគ្នា’ (fair go) ។ នេះមានន័យថាអ្វីដែលមនុស្សណាម្នាក់សម្រេចបាននៅក្នុងជីវិតគួរតែជាលទ្ធផលនៃទេពកោសល្យ ការងារ និងការខិតខំប្រឹងប្រែងរបស់ពួកគេ ជាជាងដោយសារទ្រព្យសម្បត្តិ ឬក៏ប្រវត្តិរបស់ពួកគេ ។ នេះគឺដើម្បីធានាថាគ្មានការបែងចែកវណ្ណៈជាផ្លូវការនៅក្នុងសង្គមអូស្ត្រាលី ។

ការទទួលខុសត្រូវ និងអភ័យឯកសិទ្ធិរបស់ពលរដ្ឋអូស្ត្រាលី

នៅពេលលោកអ្នកក្លាយជាពលរដ្ឋអូស្ត្រាលី លោកអ្នកនឹងមានការទទួលខុសត្រូវ និងអភ័យឯកសិទ្ធិបន្ថែម ។

ការទទួលខុសត្រូវ—អ្វីដែលលោកអ្នកនឹងផ្តល់ជូនប្រទេសអូស្ត្រាលី

ក្នុងនាមជាពលរដ្ឋអូស្ត្រាលីមួយរូប លោកអ្នកត្រូវ៖

- គោរពច្បាប់នៃប្រទេសអូស្ត្រាលី
- បោះឆ្នោតនៅក្នុងពេលបោះឆ្នោតសហព័ន្ធ និងរដ្ឋ ឬក៏ដែនដី ហើយនិងក្នុងការធ្វើប្រជាមតិ
- ការពារប្រទេសអូស្ត្រាលី ប្រសិនបើតម្រូវការកើតឡើង
- ចូលមប្រើនៅក្នុងគណៈវិនិច្ឆ័យនៅតុលាការ ប្រសិនបើត្រូវបានកោះហៅឱ្យធ្វើដូច្នោះ ។

អភ័យឯកសិទ្ធិ—អ្វីដែលប្រទេសអូស្ត្រាលីនឹងផ្តល់ជូនលោកអ្នក

ក្នុងនាមជាពលរដ្ឋអូស្ត្រាលីមួយរូប លោកអ្នកអាច៖

- បោះឆ្នោតនៅក្នុងពេលបោះឆ្នោតសហព័ន្ធ និងរដ្ឋ ឬក៏ដែនដី ហើយនិងក្នុងការធ្វើប្រជាមតិ
- ដាក់ពាក្យសុំចុះសញ្ជាតិអូស្ត្រាលីឱ្យកូនដែលកើតនៅបរទេសតាមតំណវង្សត្រកូល
- ដាក់ពាក្យសុំការងារធ្វើនៅសេវាសាធារណៈរបស់ប្រទេសអូស្ត្រាលី ឬក៏ក្នុងជួរកងកម្លាំងការពារប្រទេសអូស្ត្រាលី
- ស្វែងរកការបោះឆ្នោតជ្រើសតាំងសម្រាប់រដ្ឋសភា
- ដាក់ពាក្យសុំលិខិតឆ្លងដែនអូស្ត្រាលី និងចេញចូលប្រទេសអូស្ត្រាលីបានដោយសេរី
- សុំជំនួយផ្នែកកុងស៊ុលពីមន្ត្រីអូស្ត្រាលីនៅពេលនៅក្រៅប្រទេស ។

ការទទួលខុសត្រូវ

គោរពច្បាប់នៃប្រទេសអូស្ត្រាលី

តំណាងរបស់យើងនៅក្នុងរដ្ឋាភិបាលធ្វើច្បាប់ដើម្បីរក្សាសង្គមឱ្យមានសណ្តាប់ធ្នាប់ សេរីភាព និងសុវត្ថិភាព ហើយនិងដើម្បីការពារសិទ្ធិរបស់យើង ។ ជនជាតិអូស្ត្រាលីទាំងអស់ និងមនុស្សផ្សេងទៀតដែលរស់នៅក្នុងប្រទេសអូស្ត្រាលី ត្រូវតែគោរពច្បាប់នៃប្រទេសអូស្ត្រាលី ។

សម្រាប់ព័ត៌បន្ថែមស្តីពីច្បាប់សំខាន់ៗមួយចំនួននៅក្នុងប្រទេសអូស្ត្រាលីអាចរកឃើញនៅក្នុង *ផ្នែកទី3 ស្តីពីរដ្ឋាភិបាល និងច្បាប់នៅក្នុងប្រទេសអូស្ត្រាលី* ។

ការបោះឆ្នោតនៅក្នុងពេលបោះឆ្នោតសហព័ន្ធ និងរដ្ឋ ឬក៏ដែនដី ហើយនិងក្នុងការធ្វើប្រជាមតិ

ការបោះឆ្នោតគឺជាការទទួលខុសត្រូវ សិទ្ធិ និងអភ័យឯកសិទ្ធិសំខាន់មួយសម្រាប់ពលរដ្ឋអូស្ត្រាលីទាំងអស់ដែលមានអាយុ 18ឆ្នាំឡើងទៅ ។

វាជាការទទួលខុសត្រូវមួយសម្រាប់ពលរដ្ឋអូស្ត្រាលីទាំងអស់ដែលមានអាយុ 18ឆ្នាំឡើង ដើម្បីទៅបោះឆ្នោតនៅក្នុងពេលបោះឆ្នោតសហព័ន្ធ និងរដ្ឋ ឬក៏ដែនដី ហើយនិងក្នុងការធ្វើប្រជាមតិ ដែលជាការបោះឆ្នោតមួយដើម្បីកែប្រែរដ្ឋធម្មនុញ្ញប្រទេសអូស្ត្រាលី ។ ដោយបានបោះឆ្នោត ពលរដ្ឋអូស្ត្រាលីមានសម្លេងនៅក្នុងរបបៀបគ្រប់គ្រងប្រទេសអូស្ត្រាលី ហើយនិងចូលរួមវិភាគទានដល់អនាគតរបស់ប្រទេស ។

ការបោះឆ្នោតគឺជាកាតព្វកិច្ចដែលខានមិនបាននៅក្នុងការបោះឆ្នោតសហព័ន្ធ និងរដ្ឋ ឬក៏ដែនដី ។ ការបោះឆ្នោតអាចមិនមែនជាកាតព្វកិច្ចដែលខានមិនបាននៅក្នុងការបោះឆ្នោតរដ្ឋាភិបាលមូលដ្ឋាននៅក្នុងរដ្ឋមួយចំនួន ។

សម្រាប់ព័ត៌បន្ថែមស្តីពីរដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលីអាចរកឃើញនៅក្នុង *ផ្នែកទី3 ស្តីពីរដ្ឋាភិបាល និងច្បាប់នៅក្នុងប្រទេសអូស្ត្រាលី* ។

ការពារប្រទេសអូស្ត្រាលី ប្រសិនបើតម្រូវការកើតឡើង

ក្នុងខណៈដែលការបម្រើក្នុងកងកម្លាំងការពារប្រទេសអូស្ត្រាលីគឺជាការស្ម័គ្រចិត្ត ការទទួលខុសត្រូវសម្រាប់ពលរដ្ឋអូស្ត្រាលីគឺដើម្បីការពារប្រទេសអូស្ត្រាលី ប្រសិនបើតម្រូវការកើតឡើង ។ វាជាការសំខាន់ណាស់ដែលពលរដ្ឋអូស្ត្រាលីទាំងអស់មានការប្តេជ្ញាចិត្តដើម្បីចូលរួមជាមួយគ្នាដើម្បីការពារប្រជាជាតិ ហើយនិងរបៀបរស់នៅរបស់ខ្លួន ប្រសិនបើចាំបាច់ ។

ចូលមប្រើនៅក្នុងគណៈវិនិច្ឆ័យនៅតុលាការ ប្រសិនបើត្រូវបានកោះហៅឱ្យធ្វើដូច្នោះ

ចូលមប្រើនៅក្នុងគណៈវិនិច្ឆ័យនៅតុលាការ ប្រសិនបើត្រូវបានតុលាការស្នើ គឺជាការទទួលខុសត្រូវសម្រាប់ជនជាតិអូស្ត្រាលីដែលមានអាយុ 18ឆ្នាំឡើង ។ គណៈវិនិច្ឆ័យនៅតុលាការគឺជាក្រុមបុរស និងស្ត្រីអូស្ត្រាលីធម្មតាដែលស្តាប់ភស្តុតាង
នៅក្នុងរឿងក្តីតុលាការមួយ ហើយសម្រេចថាតើជនណាម្នាក់មានទោស ឬក៏គ្មានទោស ។

ពលរដ្ឋអូស្ត្រាលីដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតអាចត្រូវកោះហៅឱ្យបម្រើនៅក្នុងគណៈវិនិច្ឆ័យនៅតុលាការ ។ ការបម្រើក្នុងគណៈវិនិច្ឆ័យនៅតុលាការជួយធានាថាប្រព័ន្ធតុលាការបើកចំហរ និងមានយុត្តិធម៌ ។

អភ័យឯកសិទ្ធិ

ដាក់ពាក្យសុំធ្វើការនៅក្នុងសេវាសាធារណៈអូស្ត្រាលី និងបម្រើនៅក្នុងជួរកងកម្លាំងការពារប្រទេសអូស្ត្រាលី ។

អភ័យឯកសិទ្ធិនៃការមានសញ្ជាតិអូស្ត្រាលីគឺអាចដាក់ពាក្យសុំការងារធ្វើនៅក្នុងសេវាសាធារណៈអូស្ត្រាលី និងបម្រើការងារឱ្យរដ្ឋាភិបាលអូស្ត្រាលី ឧទាហរណ៍ដូចជានៅក្រសួងផ្តល់សេវាអូស្ត្រាលី (Services Australia) ឬក្រសួងពន្ធដារអូស្ត្រាលី ។

ពលរដ្ឋអូស្រាលីក៏មានសិទ្ធិដាក់ពាក្យសុំធ្វើការនៅក្នុងជួរកងកម្លាំងការពារប្រទេសអូស្ត្រាលី (កងទ័ពជើងគោក កងទ័ពជើងទឹក និងកងទ័ពជើងអាកាស) ។

ស្វែងរកការបោះឆ្នោតសម្រាប់រដ្ឋសភា

ពលរដ្ឋអូស្ត្រាលីដែលមានអាយុ 18ឆ្នាំឡើងទៅ ហើយអ្នកដែលគ្មានសញ្ជាតិពីរអាចស្វែងរកការបោះឆ្នោតសម្រាប់សភាថ្នាក់សហព័ន្ធ ថ្នាក់រដ្ឋ ឬដែនដីបាន ។ នេះគឺជាកិត្តិយស និងការទទួលខុសត្រូវដ៏ខ្ពស់ក្នុងការបម្រើការងារនៅក្នុងរដ្ឋសភាអូស្ត្រាលី ។

ដាក់ពាក្យសុំលិខិតឆ្លងដែនអូស្ត្រាលី និងចេញចូលប្រទេសអូស្ត្រាលីបានដោយសេរី

នៅពេលលោកអ្នកក្លាយជាពលរដ្ឋអូស្ត្រាលី លោកអ្នកមានសិទ្ធិរស់នៅដោយសេរីនៅក្នុងប្រទេសអូស្ត្រាលី ។ លោកអ្នកក៏មានអភ័យឯកសិទ្ធិដាក់ពាក្យសុំលិខិតឆ្លងដែនអូស្ត្រាលីបានដែរ ។ ប្រសិនបើលោកអ្នកធ្វើដំណើរទៅបរទេសក្នុងនាមជាពលរដ្ឋអូស្ត្រាលីមួយរូប លោកអ្នកចូលប្រទេសអូស្ត្រាលីវិញដោយសេរី ដោយមិនត្រូវការទិដ្ឋាការទេ ។

សុំជំនួយផ្នែកកុងស៊ុលពីមន្ត្រីអូស្ត្រាលីនៅពេលនៅក្រៅប្រទេស

ប្រទេសអូស្ត្រាលីមានស្ថានទូត ឧត្តមស្នងការដ្ឋាន ឬស្ថានកុងស៊ុលនៅប្រទេសជាច្រើន ។ ក្នុងពេលដែលលោកអ្នកស្នាក់នៅក្រៅប្រទេស លោកអ្នកអាចសុំជំនួយពីមន្ត្រីរដ្ឋាភិបាលអូស្ត្រាលីបាន នៅពេលមានការចំាបាច់ ។ នេះរាប់បញ្ចូលទំាងករណីភាពអាសន្នដូចជាការបះបោររបស់ពលរដ្ឋ និងគ្រោះធម្មជាតិ ។

មន្ត្រីអូស្ត្រាលីក៏អាចជួយពលរដ្ឋអូស្ត្រាលីនៅក្រៅប្រទេសបានដែរក្នុងការដោះស្រាយបញ្ហាត្រូវការលិខិតឆ្លងដែនជាបន្ទាន់ និងផ្តល់ដំបូន្មាន ហើយគំាទ្រនៅក្នុងករណីមានគ្រោះថ្នាក់ ជំងឺធ្ងន់ធ្ងរ ឬការស្លាប់ ។

នៅពេលស្នាក់នៅក្នុងប្រទេសមួយផ្សេងទៀត លោកអ្នកត្រូវតែគោរពច្បាប់របស់ប្រទេសនោះ ។

ដាក់ពាក្យសុំចុះសញ្ជាតិអូស្ត្រាលីឱ្យកូនដែលកើតនៅបរទេសតាមតំណវង្សត្រកូល

ពលរដ្ឋអូស្ត្រាលីអាចដាក់ពាក្យសុំចុះសញ្ជាតិអូស្ត្រាលីឱ្យកូនដែលកើតនៅបរទេសតាមតំណវង្សត្រកូលបាន ។

ការចូលរួមនៅក្នុងសង្គមអូស្ត្រាលី

ប្រទេសអូស្ត្រាលីលើកទឹកចិត្តឱ្យពលរដ្ឋទំាងអស់ចូលរួមយ៉ាងសកម្មនៅក្នុងសង្គម ។ ពលរដ្ឋសកម្មមានការទទួលខុសត្រូវ និងអភ័យឯកសិទ្ធិក្នុងការកសាងអនាគតរបស់ប្រទេសអូស្ត្រាលី ។ ឧទាហរណ៍ លោកអ្នកអាចូលរួមក្រុមសាមគ្គីអ្នកជិតខាង (neighbourhood) និងអង្គការ សហគមន៍ក្នុងតំបន់ ស្ម័គ្រចិត្តធ្វើការងារសង្គមកិច្ច និងសហគមន៍ ចូលរួមអង្គការសិល្បៈ និងវប្បធម៌ ហើយនិង ចូលរួមយ៉ាងសកម្មនៅក្នុងជីវិតនយោបាយ ។

ការបង់ពន្ធដារគឺជាវិធីមួយផ្សេងទៀតដែលលោកអ្នកផ្តល់វិភាគទានដោយផ្ទាល់ទៅដល់សហគមន៍អូស្ត្រាលី និងត្រូវបានតម្រូវដោយច្បាប់ ។ ពន្ធដារត្រូវបង់ចេញពីប្រាក់ដែលលោកអ្នករកបាន មិនថាវាបានមកពីការងារ អាជីវកម្ម ឬការវិនិយោគឡើយ ហើយត្រូវប្រមូលដោយក្រសួងពន្ធដារអូស្ត្រាលី (ATO) ។ ក៏មានពន្ធលើទំនិញ និងសេវាដែរ ។ ក្រសួងពន្ធដារអូស្ត្រាលី (ATO) ធ្វើការងារដើម្បីធានាថាពលរដ្ឋទំាងអស់បានយល់ដឹងពីសិទ្ធិ និងកាតព្វកិច្ចពន្ធដាររបស់ពួកគេដើម្បីបង់ពន្ធដារឱ្យត្រឹមត្រូវតាមចំនួន ។

ផលប្រយោជន៍ជាច្រើនដែលជនជាតិអូស្ត្រាលីបានទទួលគឺធ្វើទៅបានតាមរយៈពន្ធដារ ។ ពន្ធដារត្រូវបានចំណាយទៅលើសេវានានាដោយរាប់បញ្ចូលទំាងសេវាសុខាភិបាល និងអប់រំ ការការពារជាតិ ថ្នល់ និងផ្លូវរថភ្លើង ហើយនិងសន្តិសុខសង្គមដែលទទួលថិកាពីរដ្ឋាភិបាល ។

ដោយធ្វើការ និងបង់ពន្ធដារ លោកអ្នកគំាទ្ររដ្ឋាភិបាលផ្តល់សេវាសំខាន់ៗទំាងនេះទៅដល់សហគមន៍អូស្ត្រាលី ។ រដ្ឋាភិបាលរដ្ឋ និងដែនដី ហើយនិងក្រុមប្រឹក្សាមូលដ្ឋានក៏ប្រមូលពន្ធដារដែរដើម្បីបង់ថ្លៃសេវាទំាងនេះ ។ សេវាទំាងនេះជួយធ្វើឱ្យប្រទេសអូស្ត្រាលីជាប្រទេសដែលមានសន្តិភាព និងភាពចម្រើនរុងរឿងបានដូចសព្វថ្ងៃនេះ ។

ផ្នែកទីបី

រដ្ឋាភិបាល និង ច្បាប់នៅក្នុងប្រទេសអូស្ត្រាលី

រដ្ឋាភិបាល និងច្បាប់ នៅក្នុងប្រទេសអូស្ត្រាលី

នៅក្នុងពិធីចូលសញ្ជាតិ លោកអ្នកធ្វើសច្ចាប្រណិធានដើម្បីប្រកាន់ខ្ជាប់ និងគោរពតាមច្បាប់របស់ប្រទេសអូស្ត្រាលី ។ ប្រព័ន្ធរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីគឺលិទ្ធិប្រជាធិបតេយ្យតាមរយៈសភា ។ វាជាការសំខាន់សម្រាប់លោកអ្នកដើម្បីយល់ដឹងពីប្រព័ន្ធរដ្ឋាភិបាលនេះ របៀបធ្វើច្បាប់នៅក្នុងលទ្ធិប្រជាធិបតេយ្យតាមបែបសភា និងរបៀបគ្រប់គ្រងច្បាប់ ។ វាក៏មានសារៈសំខាន់ផងដែរត្រូវយល់ដឹងថាក្នុងនាមជាពលរដ្ឋមួយរូប លោកអ្នកនឹងបញ្ចេញសម្លេងនៅក្នុងការដឹកនាំប្រទេសតាមរបៀបណា ។

តើខ្ញុំបញ្ចេញសម្លេងរបស់ខ្ញុំដោយរបៀបណា?

ការបោះឆ្នោត

ដូចដែលបានគូសបញ្ជាក់នៅក្នុងផ្នែកទី 2 នៅក្នុងប្រទេសអូស្ត្រាលី ពលរដ្ឋដែលមានអាយុចាប់ពី 18ឆ្នាំឡើងទៅត្រូវតែចុះឈ្មោះបោះឆ្នោតនៅក្នុងការបោះឆ្នោតថ្នាក់សហព័ន្ធ រដ្ឋ និងដែនដី ហើយការធ្វើប្រជាមតិទៅលើការកែប្រែរដ្ឋធម្មនុញ្ញ ។

នៅក្នុងលទ្ធិប្រជាធិបតេយ្យតាមរយៈសភារបស់ប្រទេសអូស្ត្រាលី ពលរដ្ឋបញ្ចេញសម្លេងទៅលើរបៀបគ្រប់គ្រងប្រទេសអូស្ត្រាលីដោយធ្វើការបោះឆ្នោតឱ្យមនុស្សមួយរូបធ្វើជាតំណាងរបស់ពួកគេនៅក្នុងសភា ។ ប្រសិនបើលោកអ្នកមិនបានចុះឈ្មោះត្រឹមត្រូវទេ លោកអ្នកមិនអាចបោះឆ្នោតនៅក្នុងការបោះឆ្នោតបានទេ ។

ការបោះឆ្នោតគឺជាកាតព្វកិច្ចដែលមិនអាចខានបាននៅក្នុងការបោះឆ្នោតអូស្ត្រាលី ឬប្រសិនបើមានការធ្វើប្រជាមតិទៅលើការកែប្រែរដ្ឋធម្មនុញ្ញ ។

គណៈកម្មការបោះឆ្នោតអូស្ត្រាលី (AEC) គឺជាទីភ្នាក់ងារកុំម៉ន់វេលដែលទទួលខុសត្រូវ សម្រាប់ការធ្វើការបោះឆ្នោតថ្នាក់សហព័ន្ធ និងប្រជាមតិ ហើយនិងសម្រាប់ការ រក្សាបញ្ជីឈ្មោះបោះឆ្នោតកុំម៉ន់វេល ។ គណៈកម្មការបោះឆ្នោតអូស្ត្រាលី (AEC) គឺឯករាជ្យពីរដ្ឋាភិបាល ។ បក្សនយោបាយ ឬមនុស្សក្នុងរដ្ឋាភិបាលមិនអាចមានឥទ្ធិពលទៅលើការសម្រេចរបស់គណៈកម្មការបោះឆ្នោតអូស្ត្រាលី (AEC) បានទេ ។

ក្នុងប្រទេសអូស្ត្រាលី ការបោះឆ្នោតនៅក្នុងការបោះឆ្នោតគឺធ្វើឡើងដោយសន្លឹកឆ្នោតសម្ងាត់ ដើម្បីឱ្យលោកអ្នកមានសេរីភាព និងសុវត្ថិភាពដើម្បីបោះឆ្នោតឱ្យបេក្ខជនណាម្នាក់ ។ គ្មានជនណាម្នាក់ត្រូវបានអនុញ្ញាតឱ្យដឹងពីអ្នកដែលលោកអ្នកបានបោះឆ្នោតឱ្យនោះទេ លុះត្រាតែលោកអ្នកជ្រើសរើសប្រាប់ពួកគេ ។ ប្រសិនបើលោកអ្នកមិនបោះឆ្នោតនៅក្នុងការបោះឆ្នោត ហើយមិនមានហេតុផលល្អបញ្ជាក់ពីការមិនបានបោះឆ្នោតទេ លោកអ្នកអាចត្រូវបង់ការផាកពិន័យ ។ ការបោះឆ្នោតជាប់កាតព្វកិច្ចដែលខានមិនបានគឺជាវិធីមួយដើម្បីធានាថាមនុស្សបញ្ចេញសម្លេងទៅលើអ្នកដែលនឹងគ្រប់គ្រង និងធ្វើជាតំណាងឱ្យពួកគេនៅក្នុងសភា ។

ការលើកឡើងបញ្ហាជាមួយអ្នកតំណាងរបស់អ្នក

ពលរដ្ឋអូស្ត្រាលីអាចទាក់ទងអ្នកតំណាងជាប់ឆ្នោតរបស់ពួកគេដើម្បីលើកឡើងពីក្តីបារម្ភនានារបស់ពួកគេស្តីពីគោលនយោបាយរបស់រដ្ឋាភិបាល ។ តាមវិធីនេះ ជនជាតិអូស្ត្រាលីទាំងអស់អាចបញ្ចេញសម្លេងនៅក្នុងការបង្កើតច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាល ។ ប្រសិនបើពលរដ្ឋមួយរូបប្រាប់តំណាងជាប់ឆ្នោតរបស់គេថាច្បាប់ត្រូវតែកែប្រែ តំណាងជាប់ឆ្នោតនោះគួរពិចារណាលើអ្វីដែលបានស្នើឡើង ។

តើយើងបានបង្កើតប្រព័ន្ធរដ្ឋាភិបាលរបស់យើងដោយរបៀបណា?

សហព័ន្ធ

បន្ទាប់ពីការតាំងលំនៅដ្ឋានរបស់ចក្រភពអង់គ្លេស និងនៅមុនឆ្នាំ 1901 ប្រទេសអូស្ត្រាលីមានអាណានិគមចក្រភពអង់គ្លេសដែលគ្រប់គ្រងដោយខ្លួនឯង ហើយនៅដាច់ដោយឡែកពីគ្នាចំនួនប្រាំមួយ ។

អាណានិគមនីមួយៗមានរដ្ឋធម្មនុញ្ញ និងច្បាប់ផ្ទាល់ខ្លួនទាក់ទងនឹងការការពារជាតិ អន្តោប្រវេសន៍ ប្រៃសណីយ៍ ពាណិជ្ជកម្ម និងការដឹកជញ្ជូន ។ ក៏ប៉ុន្តែ ការនៅបែកគ្នានេះបានបង្កើតឧបសគ្គរវាងអាណានិគមទាំងនេះ ។ ឧទាហរណ៍ ពាណិជ្ជកម្ម និងការដឹកជញ្ជូនរវាងអាណានិគមទាំងនេះមានតម្លៃខ្ពស់ និងមានភាពយឺតយ៉ាវ ហើយការអនុវត្តច្បាប់នៅតាមព្រំដែនមានការពិបាក ។ អាណានិគមដែលនៅដាច់ដោយឡែកពីគ្នាទាំងនេះក៏មានប្រព័ន្ធការពារជាតិខ្សោយដែរ ។

ដោយសារហេតុនេះ មនុស្សបានចង់បង្រួបបង្រួមអាណានិគមទាំងនេះដើម្បីបង្កើតប្រជាជាតិតែមួយ ។ សំខាន់ជាងនេះ អត្តសញ្ញាណជាតិរបស់ប្រទេសអូស្ត្រាលីបានចាប់ផ្ដើមមានរូបរាងឡើង ។ ក្រុមកីឡានានាបានធ្វើជាតំណាងឱ្យប្រទេសអូស្ត្រាលីនៅអន្តរជាតិ ហើយវប្បធម៌អូស្ត្រាលីមួយបានអភិវឌ្ឍឡើងនៅក្នុងចម្រៀងប្រជាប្រិយ កំណាព្យ រឿង និងសិល្បៈ ។

ការបង្រួបបង្រួមប្រជាជាតិគឺជាភារៈកិច្ចដ៏ពិបាកមួយ ប៉ុន្តែពេលក្រោយមក គំនិតបង្កើតប្រជាជាតិអូស្ត្រាលីតែមួយបានក្លាយជាការពិត ។ នៅថ្ងៃទី1 ខែមករា ឆ្នាំ1901 អាណានិគមទាំងនេះបានរួបរួមគ្នាទៅជាសហព័ន្ធនៃរដ្ឋមួយដែលមានឈ្មោះថា កុំម៉ន់វែលអូស្ត្រាលី (Commonwealth of Australia) ។

រដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលី

ច្បាប់រដ្ឋធម្មនុញ្ញរបស់កុំម៉ន់វែលអូស្ត្រាលីឆ្នាំ 1900 (រដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលី) គឺជាឯកសារស្របច្បាប់ដែលចែងពីបទបញ្ញត្តិមូលដ្ឋានសម្រាប់រដ្ឋាភិបាលអូស្ត្រាលី ។ កាលដើមឡើយ រដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលីបានអនុម័តជាផ្នែកមួយនៃច្បាប់រដ្ឋធម្មនុញ្ញរបស់ចក្រភពអង់គ្លេសនៅឆ្នាំ 1900 ។ នៅថ្ងៃទី1 ខែមករា ឆ្នាំ1901 រដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលីបានចូលជាធរមាន ហើយអាណានិគមនានាបានក្លាយជាប្រជាជាតិឯករាជ្យមួយគឺកុំម៉ន់វែលអូស្ត្រាលី (Commonwealth of Australia) ។

រដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលីបានបង្កើតសភាកុំម៉ន់វែលអូស្ត្រាលី (Commonwealth of Australia) ដែលមានសភាតំណាងរាស្ត្រនិងព្រឹទ្ធសភា ។ រដ្ឋធម្មនុញ្ញនេះក៏បានបង្កើតតុលាការជាន់ខ្ពស់នៃប្រទេសអូស្ត្រាលីដែរ ដែលមានអំណាចស្ថាពរដើម្បីអនុវត្ត និងបកស្រាយច្បាប់របស់ប្រទេសអូស្ត្រាលី ។

ជនជាតិអូស្ត្រាលីអាចកែប្រែរដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលីបានដោយបោះឆ្នោតនៅក្នុងការធ្វើប្រជាមតិ ដូចជាការធ្វើប្រជាមតិនៅឆ្នាំ1967 ដែលមានជនជាតិអូស្ត្រាលីចំនួនជាង 90 ភាគរយបានបោះឆ្នោតថា 'យល់ព្រម' ដើម្បីអនុញ្ញាតឱ្យជនជាតិដើមអាបូរីជីនីបានរាប់បញ្ចូលក្នុងជំរឿនប្រជាជន ។

នៅក្នុងការធ្វើប្រជាមតិមួយ មានតម្រូវការចំនួនភាគច្រើនពីរដងដើម្បីកែប្រែរដ្ឋធម្មនុញ្ញ នៃប្រទេសអូស្ត្រាលីបាន ។ នេះមានន័យថាចំនួនភាគច្រើននៃអ្នកបោះឆ្នោតនៅក្នុងរដ្ឋភាគច្រើន ហើយចំនួនភាគច្រើននៃអ្នកបោះឆ្នោតនៅទូទាំងប្រទេសត្រូវបោះឆ្នោតគាំទ្រការកែប្រែ ។



រដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលី

តើអំណាចរបស់រដ្ឋាភិបាលត្រូវបានត្រួតពិនិត្យយ៉ាងដូចម្ដេច?

រដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលីបែងចែកអំណាចរបស់រដ្ឋាភិបាល រវាងអំណាចនីតិបញ្ញត្តិ (សភា) អំណាចនីតិប្រតិបត្តិ (ឧទាហរណ៍នាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី)និង អំណាចតុលាការ (ចៅក្រម) ដើម្បីបញ្ឈប់ជនម្នាក់ ឬជនមួយក្រុមពីការក្ដោបអំណាចទាំងអស់។

អំណាចនីតិបញ្ញត្តិ

អំណាចនីតិបញ្ញត្តិគឺជាអំណាចធ្វើច្បាប់។ សភាមានអំណាចដើម្បីធ្វើ និងកែប្រែច្បាប់នៅក្នុងប្រទេសអូស្ត្រាលី។ សភាបង្កើតឡើងដោយតំណាងនានាដែលជ្រើសតាំងដោយប្រជាជនអូស្ត្រាលីតាមរយៈការបោះឆ្នោត។

អំណាចនីតិប្រតិបត្តិ

អំណាចនីតិប្រតិបត្តិគឺជាអំណាចដាក់ច្បាប់ឱ្យអនុវត្ត។ អង្គនីតិប្រតិបត្តិរាប់បញ្ចូលទាំងនាយករដ្ឋមន្ត្រី មន្ត្រីរដ្ឋាភិបាលអូស្ត្រាលី និងអគ្គទេសាភិបាល។ រដ្ឋមន្ត្រីទទួលខុសត្រូវចំពោះក្រសួងរដ្ឋាភិបាល។

អំណាចតុលាការ

អំណាចតុលាការគឺជាអំណាចបកស្រាយ និងអនុវត្តច្បាប់។ តុលាការ និងចៅក្រមគឺឯករាជ្យពីសភា និងរដ្ឋាភិបាល។

អំណាចទាំងនេះត្រូវបានសរសេរនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលី។

តើនរណាជាប្រមុខរដ្ឋនៃប្រទេសអូស្ត្រាលី?

ប្រមុខរដ្ឋរបស់ប្រទេសអូស្ត្រាលីគឺព្រះមហាក្សត្រនៃប្រទេសអូស្ត្រាលី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឆាលទី III (King Charles III)។

ប្រមុខរដ្ឋរបស់ប្រទេសអូស្ត្រាលីគឺព្រះមហាក្សត្រនៃប្រទេសអូស្ត្រាលី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឆាលទី III (King Charles III)។ ព្រះមហាក្សត្រនៃប្រទេសអូស្ត្រាលីតែងតាំងអគ្គទេសាភិបាលជាព្រះរាជតំណាងរបស់ព្រះអង្គនៅក្នុងប្រទេសអូស្ត្រាលី តាមដំបូន្មានពីរដ្ឋាភិបាលអូស្ត្រាលី។ ព្រះមហាក្សត្រមិនមានព្រះរាជតួនាទីប្រចាំថ្ងៃនៅក្នុងរដ្ឋាភិបាលទេ។

នៅក្នុងរដ្ឋនីមួយៗមានទេសាភិបាលម្នាក់ដែលតំណាង ព្រះមហាក្សត្រក្នុងតួនាទីមួយដែលស្រដៀងនឹងអគ្គទេសាភិបាល។



ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ឆាលទី III (King Charles III)

របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ

ប្រទេសអូស្ត្រាលីគឺប្រកាន់របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញដែលមានន័យថាព្រះមហាក្សត្រគឺជាប្រមុខរដ្ឋនៃប្រទេសអូស្ត្រាលី ប៉ុន្តែត្រូវបំពេញព្រះរាជ សកម្មភាពឱ្យស្របតាមរដ្ឋធម្មនុញ្ញ។ ដោយសារព្រះមហាក្សត្រមិនរស់នៅក្នុងប្រទេសអូស្ត្រាលី ព្រះរាជអំណាចរបស់ព្រះអង្គត្រូវបានផ្ទេរទៅឱ្យអគ្គ ទេសាភិបាលប្រចាំនៅប្រទេសអូស្ត្រាលី។

ប្រព័ន្ធនៃលិទ្ធិប្រជាធិបតេយ្យតាមរយៈសភារបស់ប្រទេសអូស្ត្រាលីឆ្លុះបញ្ចាំងទៅលើប្រពៃណីរបស់ចក្រភពអង់គ្លេស និងអាមេរិកខាងជើងដែលបានដាក់បញ្ចូលគ្នាតាមវិធីមួយ ដែលជារបស់ប្រទេសអូស្ត្រាលីសុទ្ធសាធ។ នៅក្នុងប្រព័ន្ធអូស្ត្រាលី អ្នកដឹកនាំរដ្ឋាភិបាលគឺជានាយករដ្ឋមន្ត្រី។

តួនាទីរបស់អគ្គទេសាភិបាល

អគ្គទេសាភិបាលមិនមែនជាផ្នែកមួយរបស់រដ្ឋាភិបាលទេ ហើយត្រូវរក្សាភាពអព្យាក្រិត។

តួនាទីរបស់អគ្គទេសាភិបាលរួមមាន៖

- ចុះហត្ថលេខាលើពង្រាងច្បាប់ទាំងអស់ដែលអនុម័តដោយសភាអូស្ត្រាលីឱ្យក្លាយជាច្បាប់ (នេះគេហៅថាព្រះរាជានុញ្ញាតជាផ្លូវការ - Royal Assent)
- បំពេញភារកិច្ចនៅក្នុងពិធីផ្លូវការនានា
- ផ្តល់ការយល់ព្រមចំពោះការតែងតាំងរដ្ឋាភិបាលអូស្ត្រាលី ហើយនិងរដ្ឋមន្ត្រី ចៅក្រមសហព័ន្ធ និងមន្ត្រីផ្សេងៗទៀតរបស់រដ្ឋាភិបាល។
- ចាប់ផ្តើមដំណើរការសម្រាប់ការបោះឆ្នោតសហព័ន្ធ
- ធ្វើជាអគ្គមេបញ្ជាការនៃកងកម្លាំងការពារប្រទេសអូស្ត្រាលី។

អគ្គទេសាភិបាលក៏មានអំណាចពិសេសផងដែរដែលគេស្គាល់ថាជា "ជាអំណាចបម្រុង" ដែលអាចប្រើបានតែក្នុងតែកាលៈទេសៈពិសេសប៉ុណ្ណោះ។

តើនរណាខ្លះជាអ្នកដឹកនាំនៃប្រទេសអូស្ត្រាលី?

ប្រមុខរដ្ឋ
ព្រះមហាក្សត្រនៃប្រទេសអូស្ត្រាលី

អគ្គទេសាភិបាល
តំណាងនៃប្រមុខរដ្ឋនៅក្នុងប្រទេសអូស្ត្រាលី

ទេសាភិបាល
តំណាងនៃប្រមុខរដ្ឋ នៅក្នុងរដ្ឋនីមួយៗ

នាយករដ្ឋមន្ត្រី
អ្នកដឹកនាំនៃរដ្ឋាភិបាលអូស្ត្រាលី

ប្រមុខរដ្ឋាភិបាល (Premier)
អ្នកដឹកនាំរដ្ឋាភិបាលប្រចាំរដ្ឋ

ប្រមុខរដ្ឋមន្ត្រី (Chief Minister)
អ្នកដឹកនាំរដ្ឋាភិបាលប្រចាំដែនដី

រដ្ឋមន្ត្រីរដ្ឋាភិបាល
សមាជិកសភាត្រូវបានជ្រើសរើសដោយអ្នកដឹកនាំរដ្ឋាភិបាលដើម្បីឱ្យទទួលខុសត្រូវចំពោះវិស័យមួយរបស់រដ្ឋាភិបាល

សមាជិកសភា (MP)
តំណាងរាស្ត្រអូស្ត្រាលីដែលបានជាប់ឆ្នោតនៅក្នុងសភាអូស្ត្រាលីឬក៏សភាថ្នាក់រដ្ឋ។

ព្រឹទ្ធសភា
តំណាងរដ្ឋ ឬដែនដីដែលជាប់ឆ្នោតនៅក្នុងសភាអូស្ត្រាលី

អភិបាលក្រុង ឬអភិបាលស្រុក
អ្នកដឹកនាំនៃរដ្ឋាភិបាលមូលដ្ឋាន

សមាជិកក្រុមប្រឹក្សា
សមាជិកក្រុមប្រឹក្សាមូលដ្ឋានដែលជាប់ឆ្នោត

តើប្រទេសអូស្ត្រាលីត្រូវបានគ្រប់គ្រងយ៉ាងដូចម្តេច?

រដ្ឋាភិបាលអូស្ត្រាលី

រដ្ឋាភិបាលអូស្ត្រាលីក៏ត្រូវបានគេហៅថារដ្ឋាភិបាលសហព័ន្ធ ឬក៏រដ្ឋាភិបាលកុំម៉ន់វេល។
រដ្ឋាភិបាលមានសមាជិកសភាអូស្ត្រាលីដែលមានពីរកម្រិត៖

- សភាតំណាងរាស្ត្រ
- ព្រឹទ្ធសភា

នៅក្នុងការបោះឆ្នោតសហព័ន្ធ ពលរដ្ឋអូស្ត្រាលីបោះឆ្នោតជ្រើសតាំងតំណាងសម្រាប់សភានីមួយៗ។

សភាតំណាងរាស្ត្រ

សភាតំណាងរាស្ត្រ

សភាតំណាងរាស្ត្រគឺជាសភាមួយនៅក្នុងសភាអូស្ត្រាលី ឈ្មោះផ្សេងទៀតសម្រាប់សភាតំណាងរាស្ត្រគឺសភាជាន់ទាប ឬក៏សភាប្រជាជន។

ប្រទេសអូស្ត្រាលីបានបែងចែកទៅជាមណ្ឌលបោះឆ្នោតសហព័ន្ធ។ សមាជិកសភា(MPs) ធ្វើជាតំណាងរាស្ត្រនៅក្នុងមណ្ឌលបោះឆ្នោតរបស់ពួកគេ។

ចំនួនសមាជិកសភាសម្រាប់រដ្ឋ និងដែនដីនីមួយៗគឺអាស្រ័យទៅលើចំនួនប្រជាជននៅក្នុងរដ្ឋ ឬដែនដីនោះ។ ជាទូទៅ មានសមាជិកចំនួនជាង 150 រូបដែលបានជ្រើសតាំងសម្រាប់សភាតំណាងរាស្ត្រ។

សមាជិកសភាតំណាងរាស្ត្រ និងព្រឹទ្ធសភាពិភាក្សាវែកញែកទៅលើសំណើច្បាប់ថ្មីៗនៅក្នុងសភាអូស្ត្រាលី។ តួនាទីរបស់សភាតំណាងរាស្ត្រគឺពិនិត្យពិចារណា ពិភាក្សា វែកញែក ហើយនិងបោះឆ្នោតទៅលើសំណើច្បាប់ថ្មីនានា ឬក៏ការកែប្រែច្បាប់ ហើយ ពិភាក្សាលើបញ្ហាដែលមានសារៈសំខាន់ចំពោះជាតិ។

ព្រឹទ្ធសភា

ព្រឹទ្ធសភា

ព្រឹទ្ធសភាគឺជាសភាមួយផ្សេងទៀតនៅក្នុងសភាអូស្ត្រាលី។ ជួនកាល ព្រឹទ្ធសភាត្រូវបានគេហៅថាសភាជាន់ខ្ពស់ សភាពិនិត្យឡើងវិញ ឬក៏ សភារបស់រដ្ឋ។ អ្នកបោះឆ្នោតមកពីរដ្ឋនីមួយៗក៏ជ្រើសតាំងសមាជិកព្រឹទ្ធសភាដើម្បីធ្វើជាតំណាងឱ្យពួកគេ នៅក្នុងព្រឹទ្ធសភា។ រដ្ឋទាំងអស់មានអ្នកតំណាងស្មើគ្នានៅក្នុងព្រឹទ្ធសភា ដោយមិនគិតពីទំហំ ឬចំនួនប្រជាជនឡើយ។ មានសមាជិកព្រឹទ្ធសភាសរុបចំនួន 76 រូប។ រដ្ឋនីមួយៗជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួន 12 រូប ហើយដែនដីរាជធានីអូស្ត្រាលី និង ដែនដីខាងជើងជ្រើសតាំងសមាជិកព្រឹទ្ធសភាចំនួនពីររូបសម្រាប់ដែនដីនីមួយៗ។

សមាជិកព្រឹទ្ធសភាក៏ពិនិត្យពិចារណា ពិភាក្សាវែកញែក ហើយនិងបោះឆ្នោតទៅលើសំណើច្បាប់ថ្មីនានា ឬក៏ការកែប្រែច្បាប់ ហើយពិភាក្សាលើបញ្ហាដែលមានសារៈសំខាន់ចំពោះជាតិដែរ។

រដ្ឋាភិបាលរបស់រដ្ឋ និងដែនដី

មានរដ្ឋចំនួនប្រាំមួយ និងដែនដីគោកចំនួនពីរនៅក្នុងប្រទេសអូស្ត្រាលី។ រដ្ឋាភិបាលរបស់រដ្ឋនីមួយៗមានសភា និងរដ្ឋធម្មនុញ្ញផ្ទាល់របស់ខ្លួន។ រដ្ឋាភិបាលរបស់រដ្ឋនិងដែនដីមានមូលដ្ឋាននៅក្នុងរាជធានីរបស់ខ្លួន។ អ្នកដឹកនាំនៃរដ្ឋាភិបាលរបស់រដ្ឋគឺប្រមុខរដ្ឋាភិបាល (Premier) និងអ្នកដឹកនាំនៃរដ្ឋាភិបាលរបស់ដែនដីគឺប្រមុខរដ្ឋមន្ត្រី (Chief Minister)។

រដ្ឋាភិបាលរបស់រដ្ឋធ្វើប្រតិបត្តិការតាមរបៀបស្រដៀងគ្នាទៅនឹងរដ្ឋាភិបាលអូស្ត្រាលីដែរ។ នៅក្នុងរដ្ឋនីមួយៗ ទេសាភិបាលធ្វើជាតំណាងឱ្យព្រះមហាក្សត្រនៃប្រទេសអូស្ត្រាលី។ នៅក្នុងដែនដីខាងជើង ទេសាភិបាលត្រូវបានតែងតាំងដោយអគ្គទេសាភិបាល។ តួនាទី និងការទទួលខុសត្រូវរបស់ទេសាភិបាលមានលក្ខណៈស្រដៀងទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ទេសាភិបាលរបស់រដ្ឋដែរ។

រដ្ឋមានសិទ្ធិដែលទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ក្នុងខណៈដែលដែនដីពុំមានទេ។ រដ្ឋនានាមានអំណាចដើម្បីអនុម័តច្បាប់ដោយប្រើសិទ្ធិផ្ទាល់របស់ពួកគេ ក្នុងខណៈច្បាប់របស់ដែនដីស្វ័យគ្រប់គ្រងអាចត្រូវកែប្រែ ឬក៏លុបចោលដោយរដ្ឋាភិបាលអូស្ត្រាលីក្នុងពេលណាក៏បាន។

នៅក្នុងការបោះឆ្នោតរដ្ឋ និងដែនដី ពលរដ្ឋអូស្ត្រាលីបោះឆ្នោតជ្រើសតាំងតំណាងសម្រាប់តំបន់របស់ពួកគេ។ អ្នកតំណាងទាំងនេះក្លាយជាសមាជិកសភាតំណាងរាស្ត្ររបស់រដ្ឋ ឬដែនដីដែលពាក់ព័ន្ធ។

រដ្ឋាភិបាលមូលដ្ឋាន

រដ្ឋ និងដែនដីខាងជើងត្រូវបែងចែកជាតំបន់រដ្ឋាភិបាលមូលដ្ឋានដែលអាចហៅថាក្រុង ស្រុក ទីរួមខេត្ត ឬក្រុងរដ្ឋបាល។ តំបន់នីមួយៗមានក្រុមប្រឹក្សាមូលដ្ឋានផ្ទាល់របស់ខ្លួន។ ក្រុមប្រឹក្សាមូលដ្ឋានទទួលខុសត្រូវសម្រាប់ការធ្វើផែនការ និងផ្តល់សេវាទៅដល់សហគមន៍មូលដ្ឋាន។ ពលរដ្ឋនៅក្នុងតំបន់រដ្ឋាភិបាលមូលដ្ឋាននីមួយៗបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាមូលដ្ឋានរបស់ពួកគេ។

តើរដ្ឋាភិបាលទាំងបីកម្រិតធ្វើអ្វីខ្លះ ?

ភាពខុសគ្នាសំខាន់ៗរវាងរដ្ឋាភិបាលទាំងបីកម្រិតគឺថាទោះជាការទទួលខុសត្រូវមួយចំនួនអាចជាន់គ្នាក៏ដោយ តែជាទូទៅរដ្ឋាភិបាលកម្រិតនីមួយៗផ្តល់សេវាផ្សេងៗគ្នា ។

រដ្ឋាភិបាលអូស្ត្រាលីទទួលខុសត្រូវផ្នែក ៖

ពន្ធដារ

ការគ្រប់គ្រងសេដ្ឋកិច្ចជាតិ

អន្តោប្រវេសន៍ និងការចូលសញ្ជាតិ

ជំនួយរកការងារធ្វើ

សេវាប្រៃសណីយ៍ និងបណ្តាញគមនាគមន៍

សន្តិសុខសង្គម (ប្រាក់សោធននិវត្ត និងប្រាក់ឧបត្ថម្ភគ្រួសារ)

ការការពារប្រទេស

ជំនួញ និងពាណិជ្ជកម្ម

អាកាសយានដ្ឋាន និងសុវត្ថិភាពអាកាសចរណ៍

កិច្ចការបរទេស (ទំនាក់ទំនងជាមួយប្រទេសដទៃ) ។

រដ្ឋាភិបាលរដ្ឋ និងដែនដីទទួលខុសត្រូវជាអាទិលើផ្នែក ៖

មន្ទីរពេទ្យ និងសេវាសុខាភិបាល

សាលារៀន

ផ្លូវថ្នល់ និងផ្លូវដែក

រុក្ខាប្រមាញ់

ប៉ូលីស និងសេវារថយន្តសង្គ្រោះបន្ទាន់

ការដឹកជញ្ជូនសាធារណៈ

រដ្ឋាភិបាលមូលដ្ឋាន (និងរដ្ឋាភិបាលដែនដីរាជធានីអូស្ត្រាលី) ទទួលខុសត្រូវផ្នែក ៖

សញ្ញាតាមផ្លូវថ្នល់ ការត្រួតពិនិត្យចរាចរ

ផ្លូវថ្នល់តាមមូលដ្ឋាន ផ្លូវដើរ ស្ពាន

លូបង្ហូរទឹក

ឧទ្យាន ទីធ្លាសម្រាប់ក្មេងលេង អាងហែលទឹក ទីធ្លាលេងកីឡា

ទីធ្លាសម្រាប់បោះជំរំ និងកន្លែងចតការ៉ាវ៉ាន

ការត្រួតពិនិត្យអាហារ និងសាច់

ការគ្រប់គ្រងសូរសម្លេង និងសត្វ

ការប្រមូលសម្រាម

បណ្ណាល័យក្នុងមូលដ្ឋាន សាល និងមជ្ឈមណ្ឌលសហគមន៍

បញ្ហាជាក់លាក់នៅកន្លែងមើលថែក្មេង និងកន្លែងមើលថែមនុស្សចាស់

លិខិតអនុញ្ញាតការសាងសង់

ការធ្វើផែនការសង្គម

បញ្ហាបរិស្ថានក្នុងមូលដ្ឋាន

តើគណបក្សនយោបាយនានាមានតួនាទីអ្វីខ្លះក្នុងរបៀបគ្រប់គ្រងប្រទេសអូស្ត្រាលី?

គណបក្សនយោបាយគឺជាក្រុមមនុស្សដែលចែករំលែកគំនិតស្រដៀងគ្នាអំពីថាតើប្រទេសគួរត្រូវគ្រប់គ្រងតាមរបៀបណា ។ ពួកគេធ្វើការជាមួយគ្នាដើម្បីប្រែក្លាយគំនិតបក្សរបស់ពួកគេឱ្យទៅជាច្បាប់ ។ គណបក្សនយោបាយសំខាន់ៗនៅប្រទេសអូស្ត្រាលីគឺគណបក្សសេរីនិយមអូស្ត្រាលី (Liberal Party of Australia) គណបក្សពលករអូស្ត្រាលី (Australian Labor Party) គណបក្សជាតិនិយម (Nationals) និងគណបក្សបៃតងអូស្ត្រាលី (Australian Greens) ។

សមាជិកសភាភាគច្រើនបំផុតជារបស់គណបក្សនយោបាយ ។ សមាជិកសភាមួយចំនួនមិនមែនជារបស់គណបក្សនយោបាយណាមួយឡើយ ហើយពួកគេត្រូវបានគេហៅថា 'សមាជិកសភាឯករាជ្យ' ។

នៅក្នុងប្រទេសអូស្ត្រាលី ប្រជាជនមានសេរីភាពដើម្បីចូលរួមក្នុងគណបក្សនយោបាយមួយ ប្រសិនបើពួកគេជ្រើសរើស ។

តើរដ្ឋាភិបាលអូស្ត្រាលីត្រូវបានបង្កើតឡើងយ៉ាងដូចម្តេច?

ក្រោយពីការបោះឆ្នោតសហព័ន្ធ ជាទូទៅរដ្ឋាភិបាលអូស្ត្រាលីគឺត្រូវបានបង្កើតឡើងដោយគណបក្សនយោបាយមួយ ឬក៏គណបក្សចម្រុះដែលមានសមាជិកភាគច្រើននៅក្នុងសភាតំណាងរាស្ត្រ ។ អ្នកដឹកនាំនៃគណបក្សនេះនឹងក្លាយជាអ្នកដឹកនាំប្រទេសអូស្ត្រាលីគឺ នាយករដ្ឋមន្ត្រី ។

ក្រោយពីការបោះឆ្នោតសហព័ន្ធ គណបក្សនយោបាយមួយ ឬក៏គណបក្សចម្រុះដែលមានសមាជិកច្រើនជាងគេទីពីរនៅក្នុងសភាតំណាងរាស្ត្របង្កើតគណបក្សប្រឆាំង ។ អ្នកដឹកនាំរបស់បក្សប្រឆាំងត្រូវគេហៅថាប្រធានគណបក្សប្រឆាំង ។

នាយករដ្ឋមន្ត្រីផ្តល់យោបល់ឱ្យសមាជិកសភាតំណាងរាស្ត្រ ឬក៏សមាជិកព្រឹទ្ធសភាក្លាយជារដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាលអូស្ត្រាលី ។ អគ្គទេសាភិបាលជាអ្នកចុះហត្ថលេខាយល់ព្រមទៅលើការតែងតាំងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ។

រដ្ឋមន្ត្រីរបស់រដ្ឋាភិបាលមានការទទួលខុសត្រូវសម្រាប់វិស័យមួយរបស់រដ្ឋាភិបាល (គេហៅថាមុខតំណែងតាមក្រសួង) ដូចជាក្រសួងការងារ ក្រសួងកិច្ចការជនជាតិដើម ឬក៏ក្រសួងរតនាគារជាដើម ។ រដ្ឋមន្ត្រីដែលមានមុខតំណែងសំខាន់ជាងគេបង្អស់បង្កើតគណៈរដ្ឋមន្ត្រីដែលជាអង្គធ្វើសេចក្តីសម្រេចសំខាន់របស់រដ្ឋាភិបាល ។

តើច្បាប់ត្រូវធ្វើឡើងយ៉ាងដូចម្តេច?

សភាអូស្ត្រាលីមានអំណាចធ្វើ ឬកែប្រែច្បាប់នៅក្នុងប្រទេសអូស្ត្រាលីដើម្បីបម្រើផលប្រយោជន៍ប្រជាជាតិ ។

ប្រសិនបើសមាជិកសភាតំណាងរាស្ត្រធ្វើសំណើច្បាប់ថ្មី ឬ កែប្រែច្បាប់ដែលមានស្រាប់ សំណើនេះត្រូវបានគេហៅថា 'ពង្រាងច្បាប់' ។

↓

សភាតំណាងរាស្ត្រ និងព្រឹទ្ធសភាពិនិត្យពិចារណា ជជែកវែកញែក និងបោះឆ្នោតទៅលើថាតើពួកគេយល់ស្របតាមពង្រាងច្បាប់នេះ ឬក៏មិនយល់ព្រម ។

↓

ប្រសិនបើសមាជិកភាគច្រើននៅក្នុងសភានីមួយៗយល់ស្របទៅនឹងពង្រាងច្បាប់នេះ វានឹងត្រូវបញ្ជូនទៅអគ្គទេសាភិបាល ។

↓

អគ្គទេសាភិបាលចុះហត្ថលេខាទៅលើពង្រាងច្បាប់នេះដើម្បីឱ្យវាក្លាយទៅជាច្បាប់ ។ នេះគេហៅថា 'ព្រះរាជានុញ្ញាតជាផ្លូវការ - Royal Assent' ។

សភារដ្ឋ និងសភាដែនដីធ្វើច្បាប់ផ្ទាល់ខ្លួនរបស់ពួកគេតាមវិធីស្រដៀងគ្នានេះដែរ ។

តើច្បាប់ត្រូវអនុវត្តយ៉ាងដូចម្ដេច?

តុលាការ

តុលាការនៅក្នុងប្រទេសអូស្ត្រាលីមានឯករាជ្យភាព ។ តុលាការនឹងសម្រេចថាតើជនណាម្នាក់បាន ឬមិនបានបំពានច្បាប់ និងសម្រេចទោស ។ តុលាការអាចផ្អែកការសម្រេចរបស់ពួកគេទៅលើតែភស្តុតាងនៅចំពោះមុខពួកគេប៉ុណ្ណោះ ។

ចៅក្រម និងចៅក្រមថ្នាក់ក្រោម

ចៅក្រម ឬចៅក្រមថ្នាក់ក្រោមគឺជាអាជ្ញាធរខ្ពស់បំផុតនៅក្នុងតុលាការ ។ ពួកគេឯករាជ្យ ហើយគ្មានជនណាម្នាក់អាចប្រាប់ពួកគេឱ្យសម្រេចអ្វីបានទេ ។

ចៅក្រម និងចៅក្រមថ្នាក់ក្រោមត្រូវបានតែងតាំងដោយរដ្ឋាភិបាល ក៏ប៉ុន្តែរដ្ឋាភិបាលមិនអាចដកហូតការងាររបស់ពួកគេបានទេ ប្រសិនបើរដ្ឋាភិបាលមិនយល់ស្របតាមសេចក្ដីសម្រេចរបស់ពួកគេ ។

គណៈវិនិច្ឆ័យនៅតុលាការ

នៅក្នុងប្រព័ន្ធតុលាការអូស្ត្រាលី មនុស្សត្រូវចាត់ទុកថាគ្មានទោសរហូតដល់ពួកគេត្រូវបានរកឃើញថាមានទោសនៅក្នុងតុលាការ ។ មនុស្សគ្រប់រូបមានសិទ្ធិរកមេធាវីធ្វើជាតំណាងនៅក្នុងតុលាការ ។

តុលាការនឹងប្រើគណៈវិនិច្ឆ័យនៅក្នុងសំណុំរឿងក្ដីខ្លះដើម្បីសម្រេចថាតើជនណាម្នាក់បានបំពានច្បាប់ ឬក៏មិនបំពាន ។ តួនាទីរបស់គណៈវិនិច្ឆ័យនៅតុលាការគឺដើម្បីសម្រេចនៅក្នុងតុលាការថាតើជនណាម្នាក់គ្មានទោស ឬក៏មានទោស ។ គណៈវិនិច្ឆ័យនៅតុលាការគឺជាក្រុមពលរដ្ឋអូស្ត្រាលីធម្មតាដែលជ្រើសរើសដោយគ្មានការគ្រោងទុកពីចំនួនប្រជាជនទូទៅ ។ ចៅក្រមពន្យល់ច្បាប់ទៅដល់គណៈវិនិច្ឆ័យនៅតុលាការ ។ នៅក្នុងការជំនុំជម្រះក្ដីព្រហ្មទណ្ឌ ប្រសិនបើគណៈវិនិច្ឆ័យនៅតុលាការរកឃើញថាជនណាម្នាក់មានទោស គណៈវិនិច្ឆ័យសម្រេចទោស ។

ប៉ូលីស

ប៉ូលីសថែរក្សាសន្តិភាព និងសណ្ដាប់ធ្នាប់នៅក្នុងសហគមន៍ ។ វាជាភារកិច្ចរបស់ពួកគេត្រូវការពារជីវិត និងទ្រព្យសម្បត្តិ ។ ពួកគេឯករាជ្យពីរដ្ឋាភិបាល ។ ប្រសិនបើប៉ូលីសជឿថាមានជនណាម្នាក់បានបំពានច្បាប់ ពួកគេអាចចាប់ខ្លួនពួកគេ និងនាំពួកគេឡើងទៅចំពោះមុខតុលាការច្បាប់ ។ ប៉ូលីសអាចផ្ដល់ភស្តុតាងនៅក្នុងតុលាការ ក៏ប៉ុន្តែតុលាការសម្រេចថាតើជនណាម្នាក់មានកំហុស ឬក៏គ្មានកំហុស ។

រដ្ឋ និងដែនដីខាងជើងមានកងកម្លាំងប៉ូលីសផ្ទាល់របស់ពួកគេ ។ ពួកគេដោះស្រាយរឿងឧក្រិដ្ឋកម្មនៅក្រោមច្បាប់របស់រដ្ឋ និង ដែនដី ។

ប្រទេសអូស្ត្រាលីក៏មានកងកម្លាំងប៉ូលីសជាតិដែរដែលគេហៅថាប៉ូលីសសហព័ន្ធអូស្ត្រាលី (AFP) ដែរ ។ ប៉ូលីសសហព័ន្ធអូស្ត្រាលី (AFP) ស៊ើបអង្កេតឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់សហព័ន្ធ ឧទាហរណ៍ ការជួញដូរគ្រឿងញៀន ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិសុខជាតិ និងឧក្រិដ្ឋកម្មប្រឆាំងនឹងបរិស្ថាន ។ ប៉ូលីសសហព័ន្ធអូស្ត្រាលី (AFP) ក៏ទទួលខុសត្រូវចំពោះការងារប៉ូលីសទូទៅដែរនៅក្នុងដែនដីរាជធានីអូស្ត្រាលី ។

នៅក្នុងប្រទេសអូស្ត្រាលី ប៉ូលីស និងសហគមន៍មានទំនាក់ទំនងល្អ ។ លោកអ្នកអាចរាយការណ៍ពីឧក្រិដ្ឋកម្ម និងស្វែងរកជំនួយពីប៉ូលីសប្រចាំមូលដ្ឋានរបស់លោកអ្នក ។

នៅក្នុងប្រទេសអូស្ត្រាលី ការសូកប៉ាន់ប៉ូលីសជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរមួយ ។ ទោះជាការសុំផ្ដល់សំណូកទៅមន្ត្រីប៉ូលីសក៏ជាឧក្រិដ្ឋកម្មមួយដែរ ។

បទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសអូស្ត្រាលី

វាមានសារៈសំខាន់សម្រាប់លោកអ្នកត្រូវយល់ដឹងពីច្បាប់នៅក្នុងប្រទេសអូស្ត្រាលី ។ ប្រសិនបើលោកអ្នកបំពានច្បាប់អូស្ត្រាលីដែលលោកអ្នកមិនដឹង លោកអ្នកអាចត្រូវចោទប្រកាន់ ដោយសារការមិនដឹងពីច្បាប់មិនអាចយកមកធ្វើជាការដោះសារបានទេ ។

ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតមួយចំនួនដោយរួមមានឃាតកម្ម ការរំលោភបំពានរាងកាយ ការរំលោភបំពានផ្លូវភេទ អំពើហិង្សាប្រឆាំងមនុស្ស ឬទ្រព្យសម្បត្តិ ការប្លន់ប្រដាប់អាវុធ ឬការលួច ការរួមភេទជាមួយកុមារ ឬក្មេងដែលមានអាយុក្រោមអាយុស្របច្បាប់ដើម្បីផ្តល់ការយល់ព្រម ការបើកបររថយន្តប្រកបដោយគ្រោះថ្នាក់ ការមានគ្រឿងញៀនខុសច្បាប់ និងការបោកបន្លំ ។

ជនគ្រប់រូបមានសិទ្ធិទទួលបានទំនាក់ទំនងវិជ្ជមាន និងសុវត្ថិភាពជាមួយគ្រួសារ មិត្តភក្តិរបស់ពួកគេ ហើយនិងអ្នកដែលពួកគេស្រលាញ់ ។ ដូចគ្នានៅក្នុងប្រទេសផ្សេងទៀត អំពើហិង្សាចំពោះអ្នកដទៃគឺជាអំពើខុសច្បាប់នៅក្នុងប្រទេសអូស្ត្រាលី ហើយជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរមួយ ។ នេះរាប់បញ្ចូលទាំងអំពើហិង្សានៅក្នុងផ្ទះ និងក្នុងអាពាហ៍ពិពាហ៍ដែលគេស្គាល់ថាជា អំពើហិង្សានៅក្នុងផ្ទះ និងក្នុងគ្រួសារ ។ អំពើហិង្សានៅក្នុងផ្ទះ និងក្នុងគ្រួសាររួមមានអាកប្បកិរិយា ឬការគំរាមកំហែងដែលមានបំណងត្រួតត្រាដៃគូដោយបង្កការភ័យខ្លាច ឬក៏គំរាមកំហែងសុវត្ថិភាពពួកគេ ។ អំពើហិង្សាក្នុងគ្រួសារ និងតាមផ្ទះអាចរាប់បញ្ចូលការវាយ ការបំបែបសមាជិកគ្រួសារម្នាក់ពីមិត្តភក្តិ និងគ្រួសារ ឬក៏គម្រាមកំហែងដល់កុមារ ឬសត្វចិញ្ចឹម ។ អំពើហិង្សានៅក្នុងផ្ទះ និងក្នុងគ្រួសារគឺជាអំពើមិនអាចទទួលយកបាន និងជាអំពើប្រឆាំងនឹងច្បាប់ ។

ជនណាម្នាក់ដែលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះអាចជាប់ពន្ធនាគារ មិនថាពួកគេជាបុរស ឬស្ត្រីទេ ។ គ្មានជនណាម្នាក់គួរទទួលយកអំពើអាក្រក់ ឬក៏ការរងទុក្ខឡើយ ។

ប្រសិនបើលោកអ្នក ឬនរណាម្នាក់ដែលលោកអ្នកស្គាល់មានគ្រោះថ្នាក់ លោកអ្នកគួរទាក់ទងប៉ូលីស ។ ព័ត៌មានបន្ថែមមាននៅ www.respect.gov.au and www.1800respect.org.au ។

បទល្មើសច្បាប់ចរាចរ

បទបញ្ញត្តិស្តីពីផ្លូវថ្នល់ និងចរាចរត្រូវបានត្រួតពិនិត្យដោយរដ្ឋាភិបាលរដ្ឋ និងដែនដី ។ ប្រជាជនអាចត្រូវផាកពិន័យ ឬបញ្ជូនទៅពន្ធនាគារដោយសារបំពានច្បាប់ចរាចរ ។ ដើម្បីបើករថយន្តនៅក្នុងប្រទេសអូស្ត្រាលី លោកអ្នកត្រូវមានប័ណ្ណបើកបរមូលដ្ឋាន និងរថយន្តត្រូវតែចុះលេខត្រឹមត្រូវ ។

មនុស្សគ្រប់រូបដែលធ្វើដំណើរនៅក្នុងរថយន្តត្រូវតែពាក់ខ្សែក្រវ៉ាត់ ។ ទារក និងក្មេងៗត្រូវអង្គុយនៅលើកៅអីរថយន្តដែលមានការអនុញ្ញាតត្រឹមត្រូវ ។ ច្បាប់ចរាចរមានលក្ខណៈតឹងតែងណាស់ ។ វាជាអំពើខុសច្បាប់ដែលបើកបរបន្ទាប់ពីសេពគ្រឿងញៀន ឬប្រសិនបើលោកអ្នកមានជាតិអាល់កុលនៅក្នុងឈាមលើសកម្រិត ។ វាក៏ជាអំពើខុសច្បាប់ដែរដែលប្រើប្រាស់ទូរស័ព្ទដៃនៅពេលបើកបរ ។

ផ្នែកទីបួន

គុណតម្លៃរបស់ប្រទេសអូស្ត្រាលី



គុណតម្លៃរបស់ប្រទេសអូស្ត្រាលី

គុណតម្លៃរបស់ប្រទេសអូស្ត្រាលីដែលផ្អែកទៅលើសេរីភាព ការគោរពភាពយុត្តិធម៌ និងសមភាព គឺមានសារៈសំខាន់បំផុតសម្រាប់ប្រទេសអូស្ត្រាលីដោយរក្សាឱ្យមានទីកន្លែងមួយដែលមានសន្តិសុខ ភាពចម្រើនរុងរឿង និងសន្តិភាពសម្រាប់រស់នៅ ។

គុណតម្លៃរបស់យើងកំណត់អត្តន័យ និងកសាងប្រទេស ហើយដោយសារគុណតម្លៃទាំងនេះហើយដែលមនុស្សជាច្រើនចង់ក្លាយជាជនជាតិអូស្ត្រាលី ។

ភាពជាពលរដ្ឋអូស្ត្រាលីគឺនិយាយអំពីការរស់នៅដោយប្រកាន់ខ្ជាប់នូវគុណតម្លៃទាំងនេះនៅក្នុងជីវភាពប្រចាំថ្ងៃក្នុងសហគមន៍មូលដ្ឋានរបស់លោកអ្នក ។ ហេតុដូច្នេះវាជាការសំខាន់ណាស់ដែលថាលោកអ្នកត្រូវយល់ដឹងពីគុណតម្លៃនានាដែលជនជាតិអូស្ត្រាលីទាំងអស់ត្រូវបានរំពឹងឱ្យគោរព ចែករំលែក និងប្រតិបត្តិតាម ។

គុណតម្លៃរបស់យើង

ការប្តេជ្ញាគោរពតាមនីតិរដ្ឋ

ជនជាតិអូស្ត្រាលីទាំងអស់ត្រូវបានការពារដោយច្បាប់ និងប្រព័ន្ធច្បាប់របស់យើង ។ ជនជាតិអូស្ត្រាលីទទួលស្គាល់សារៈសំខាន់នៃច្បាប់នៅក្នុងការរក្សាសង្គមមួយឱ្យមានសន្តិភាព និងសណ្តាប់ធ្នាប់ល្អ ។

នៅក្រោមនីតិរដ្ឋ ជនជាតិអូស្ត្រាលីទាំងអស់មានភាពស្មើៗគ្នាទាក់ទងនឹងច្បាប់ ហើយគ្មានជនណាម្នាក់ ឬក្រុមណាមួយនៅពីច្បាប់បានទេ ។ នៅក្នុងប្រទេសអូស្ត្រាលី មនុស្សគ្រប់រូបគួរគោរពច្បាប់ និងមិនបំពានច្បាប់នៅពេលណាមួយ បើពុំដូច្នេះទេលោកអ្នកនឹងត្រូវទទួលទោស ។ លោកអ្នកគួរអនុវត្តតាមច្បាប់ ទោះជាគ្មាននរណាម្នាក់កំពុងឃ្លាំមើលក៏ដោយ ។

ច្បាប់ប្រទេសអូស្ត្រាលីអនុវត្តចំពោះមនុស្សទាំងអស់នៅក្នុងប្រទេសអូស្ត្រាលី ។ នេះមានន័យថាលោកអ្នកត្រូវអនុវត្តតាមច្បាប់ប្រទេសអូស្ត្រាលីដោយមិនគិតពីប្រវត្តិ ឬវប្បធម៌ឡើយ ។

លិទ្ធិប្រជាធិបតេយ្យតាមរយៈសភា

ប្រព័ន្ធរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីគឺលិទ្ធិប្រជាធិបតេយ្យតាមរយៈសភា ។ ច្បាប់របស់យើងត្រូវបានកំណត់ដោយសភាដែលបានជ្រើសតាំងដោយប្រជាជន ។ នេះមានន័យថាពលរដ្ឋអូស្ត្រាលីចូលរួមនៅក្នុងរបៀបគ្រប់គ្រងប្រទេស ។. អំណាចរបស់រដ្ឋាភិបាលបានមកពីប្រជាជនអូស្ត្រាលីពីព្រោះពលរដ្ឋអូស្ត្រាលីបោះឆ្នោត ឱ្យមនុស្សធ្វើជាតំណាងរបស់ពួកគេនៅក្នុងសភា ។

ការបោះឆ្នោតគឺជាកាតព្វកិច្ចដែលខានមិនបាននៅក្នុងប្រទេសអូស្ត្រាលី ។ នេះបង្ហាញពីភាពសំខាន់នៃការចូលរួមនៅក្នុងការបោះឆ្នោត ។

សេរីភាពក្នុងការនិយាយស្ដី

មនុស្សនៅក្នុងប្រទេសអូស្ត្រាលីគួរមានលទ្ធភាពបញ្ចេញគំនិតរបស់ពួកគេដោយសេរី ឱ្យតែការបញ្ចេញគំនិតនេះស្ថិតនៅក្នុងព្រំដែនច្បាប់ ។ មនុស្សមានសេរីភាពក្នុងការជួបជុំគ្នានៅទីកន្លែងសាធារណៈ ឬក៏ឯកជនដើម្បីពិភាក្សាអំពីនយោបាយ និងសង្គម ។ មនុស្សក៏មានសេរីភាពក្នុងការនិយាយ និងសរសេរអំពីអ្វីដែលពួកគេគិតអំពីប្រធានបទណា មួយ និងពិភាក្សាគំនិតរបស់ពួកគេជាមួយមនុស្សផ្សេងទៀត ។រោងពុម្ពការសែត កន្លែងផ្សាយទូរទស្សន៍ និងវិទ្យុមានសេរីភាពដូចគ្នា ។

ជនជាតិអូស្ត្រាលីទទួលបានការអនុញ្ញាតឱ្យធ្វើការតវ៉ាប្រឆាំងនឹងសកម្មភាពរបស់រដ្ឋាភិបាលដោយសន្តិវិធី ពីព្រោះការអធ្យាស្រ័យចំពោះការប្រឆាំតវ៉ាជាសាធារណៈដោយសន្តិវិធីគឺជាផ្នែកមួយដ៏សំខាន់ នៃលទ្ធិប្រជាធិបតេយ្យ ។

វាជាការមិនអាចទទួលយកបានទេនូវការបង្កើនភាពហិង្សាប្រឆាំងនឹងមនុស្ស ឬក្រុមមនុស្សមួយផ្សេងទៀត (ដូចជាដោយសារវប្បធម៌ ជាតិសាសន៍ សាសនា ឬប្រវត្តិរបស់ពួកគេ) ពីព្រោះវាជាអំពើប្រឆាំងនឹងគុណតម្លៃ និងច្បាប់នៃប្រទេសអូស្ត្រាលី ។ វាក៏ជាការខុសច្បាប់ដែរដែលធ្វើការចោទប្រកាន់មិនពិត ឬក៏លើកទឹកចិត្តមនុស្សដទៃឱ្យបំពានច្បាប់ ។ សេរីភាពក្នុងការនិយាយស្ដី និងសេរីភាពក្នុងការសម្ដែងមតិរបស់មនុស្សដទៃទៀតត្រូវតែគោរព ឱ្យតែការសម្ដែងមតិនោះស្របតាមច្បាប់ ។

សេរីភាពក្នុងការបង្កើតសមាគម

នៅប្រទេសអូស្ត្រាលី មនុស្សមានសេរីភាពដើម្បីចូលរួម ឬចាកចេញពីក្រុមណាមួយ ដោយស្ម័គ្រចិត្ត ឱ្យតែវាស្ថិតនៅក្នុងព្រំដែនច្បាប់ ។ មនុស្សមានសេរីភាពចូលរួមអង្គការស្របច្បាប់ណាមួយ ដូចជាបក្សនយោបាយ សហជីព ក្រុមសាសនា ក្រុមវប្បធម៌ ឬក៏ក្រុមសង្គមជាដើម ។ បុគ្គលនានាមិនត្រូវបានបង្ខិតបង្ខំឱ្យចូលរួមអង្គការ ឬបង្ខំឱ្យចេញពីអង្គការណាមួយទេ ។

ជនជាតិអូស្ត្រាលីអាចជួបជុំដោយសេរីជាមួយមនុស្សផ្សេងទៀត ដោយមានរួមទាំងការ ជួបជុំដើម្បីប្រឆាំងតវ៉ាសកម្មភាពរដ្ឋាភិបាល ឬអង្គការមួយ ។ ក៏ប៉ុន្តែ ការប្រឆាំងតវ៉ាត្រូវតែធ្វើឡើងនៅក្នុងព្រំដែនច្បាប់ ។ នេះមានន័យថាពួកគេត្រូវតែធ្វើដោយសន្តិវិធី ហើយមិនត្រូវបង្ករបួសស្នាមដល់ អ្នកណាម្នាក់ ឬបង្កការខូចខាតដល់ទ្រព្យសម្បត្តិណាមួយឡើយ ។

សេរីភាពខាងជំនឿសាសនា

ប្រទេសអូស្ត្រាលីគ្មានសាសនាជាតិជាផ្លូវការទេ ហើយប្រជាជននៅក្នុងប្រទេសអូស្ត្រាលីមានសេរីភាពកាន់សាសនាណាមួយដែលពួកគេបានជ្រើសរើស ។ រដ្ឋាភិបាលចាត់ទុកលរដ្ឋទាំងអស់ស្មើៗគ្នា ទោះជាពួកគេកាន់សាសនា ឬមានជំនឿ អ្វីក៏ដោយ ។ ក៏ប៉ុន្តែការប្រតិបត្តិខាងផ្លូវសាសនាមិនត្រូវបំពានលើច្បាប់ប្រទេសអូស្ត្រាលី ។

ច្បាប់សាសនាពុំមានតួឋានៈស្របច្បាប់នៅប្រទេសអូស្ត្រាលីទេ ។ មនុស្សគ្រប់រូបនៅប្រទេសអូស្ត្រាលីត្រូវគោរពច្បាប់ប្រទេសអូស្ត្រាលី ដោយរាប់បញ្ចូលទាំងចំណុចដែលខុសពីច្បាប់សាសនា ។ ការប្រតិបត្តិខាងផ្លូវសាសនា ឬវប្បធម៌ ដូចជាពហុពន្ធភាព (ដោយរៀបការជាមួយ មនុស្សច្រើនជាងម្នាក់ក្នុងពេលដូចគ្នា) ហើយអាពាហ៍ពិពាហ៍ដោយបង្ខំគឺប្រឆាំងនឹង ច្បាប់នៅប្រទេសអូស្ត្រាលី ហើយអាចជាប់ទោដោយរួមទាំងការជាប់ពន្ធនាគារ ។

ការមិនអធ្យាស្រ័យគ្នាខាងសាសនាគឺមិនអាចទទួលយកបានទេនៅក្នុងសង្គមអូស្ត្រាលី ។ មនុស្សទាំងអស់គួរទទួលបាននូវឱកាសស្មើគ្នាៗក្នុងការស្វែងរកគោលដៅ និងចំណាប់អារម្មណ៍របស់ពួកគេ ដោយមិនគិតពីពូជសាសន៍ ឬសាសនាឡើយ ឱ្យតែពួកគេគោរពច្បាប់អូស្ត្រាលី ។

សមភាពរបស់មនុស្សទាំងអស់នៅក្រោមច្បាប់

សង្គមអូស្ត្រាលីឱ្យតម្លៃទៅលើសិទ្ធិស្មើគ្នារបស់មនុស្សទាំងអស់ ដោយមិនគិតពីភេទ ការតម្រង់ទិសផ្លូវភេទ អាយុ ពិការភាព សាសនា ពូជសាសន៍ ឬដើមកំណើតជាតិសាសន៍ ឬសញ្ជាតិទេ ។ មានច្បាប់មួយចំនួននៅក្នុងប្រទេសអូស្ត្រាលីដែលការពារមនុស្សមិនឱ្យគេចាត់ទុកពួកគេខុសប្លែកពីមនុស្សដទៃទេ ។

ច្បាប់ត្រូវបានអនុវត្តនៅក្នុងប្រទេសអូស្ត្រាលីដើម្បីឱ្យប្រជាជនមកពីប្រវត្តិខុសៗគ្នាមិនទទួលការប្រព្រឹត្តិដោយមានការអនុគ្រោះ និងមិនទទួលរងការរើសអើង ។ ឧទាហរណ៍ អ្នកកាន់សាសនាព្រះពុទ្ធ និងមនុស្សដែលកាន់ជំនឿផ្សេងទៀតទាំងអស់ទទួលបានការចាត់ទុកដូចគ្នានឹងអ្នកកាន់គ្រីស្តសាសនាដែរ ។ នៅក្រោមច្បាប់របស់យើងមនុស្សពីរនាក់អាចរៀបការជាមួយគ្នាបាន ដោយរួមទាំងអាពាហ៍ពិពាហ៍រវាងបុរសពីរនាក់ ឬស្ត្រីពីរនាក់ ។

បុរស និងស្ត្រីគួរទទួលបានសិទ្ធិស្មើគ្នានៅក្នុងប្រទេសអូស្ត្រាលី ហើយគួរទទួលបានឱកាសស្មើគ្នាដើម្បីស្វែងរកគោលដៅ និងចំណាប់អារម្មណ៍របស់ពួកគេ ។ ទាំងបុរស និងស្ត្រីមានលទ្ធភាពទទួលបានការអប់រំ និងការងារ អាចបោះឆ្នោតក្នុងការបោះឆ្នោត អាចឈរឈ្មោះសម្រាប់សភា ចូលបម្រើក្នុងកងកម្លាំងការពារប្រទេសអូស្ត្រាលី និងប៉ូលីសបាន ហើយត្រូវបានគេចាត់ទុកស្មើៗគ្នានៅក្នុងតុលាការច្បាប់ ។

វាជាអំពើប្រឆាំងនឹងច្បាប់ដែលរើសអើងប្រឆាំងនឹងមនុស្សម្នាក់ដោយសារភេទរបស់ពួកគេ ។ នៅក្នុងប្រទេសអូស្ត្រាលី វាជាសិទ្ធិសម្រាប់ស្ត្រីទទួលបានការងារមុនបុរស ប្រសិនបើនាងមានបំណិន និងគុណសម្បត្តិល្អជាង ។

ទាំងបុរស និងស្ត្រីមានសិទ្ធិធ្វើជម្រើសដោយឯករាជ្យផ្ទាល់ខ្លួនរបស់ពួកគេស្តីអំពីបញ្ហាផ្ទាល់ខ្លួននានាដូចជាអាពាហ៍ពិពាហ៍ និងសាសនា ហើយសិទ្ធិនេះត្រូវបានទទួលការការពារ ដោយច្បាប់ពីការគម្រាមកំហែង ឬអំពើហិង្សា ។ អំពើហិង្សាទៅលើរាងកាយប្រឆាំងនឹងប្តី ឬប្រពន្ធគឺជាអំពើដែលមិនអាចទទួលយកបានទេ ហើយជាបទល្មើសព្រហ្មទណ្ឌនៅក្នុងប្រទេសអូស្ត្រាលី ។

ការលែងលះគឺទទួលយកបាននៅក្នុងប្រទេសអូស្ត្រាលី ប្តី ឬក៏ប្រពន្ធអាចដាក់ពាក្យសុំលែងលះទៅតុលាការ ទោះជាប្តី ឬប្រពន្ធម្នាក់ទៀតប្រាថ្នាចង់បន្តអាពាហ៍ពិពាហ៍ក៏ដោយ ។

សមភាពនៃឱកាស និង ’ឱកាសដូចគ្នា’ (fair go)’

យើងជឿថាជនគ្រប់រូបគួរទទួលបានឱកាសដូចគ្នា (fair go) ហើយមិនគួរទទួលបានការរឹតត្បិតដោយភាពខុសគ្នានៃវណ្ណៈណាមួយនោះទេ ។ ជនគ្រប់រូបដោយមិនគិតពីប្រវត្តិរបស់ពួកគេទទួលបានឱកាសស្មើៗគ្នាដើម្បីសម្រេចភាពជោគ
ជ័យនៅក្នុងជីវិត ហើយការធានាថាជនគ្រប់រូបមានសិទ្ធិស្របច្បាប់ដូចគ្នាគឺជាផ្នែកដែលមានសារៈសំខាន់មួយនៃភាពយុត្តិធម៌នៅក្នុងសង្គមអូស្ត្រាលី ។

អ្វីដែលមនុស្សណាម្នាក់ធ្វើបានសម្រេចនៅក្នុងជីវិតគួរជាលទ្ធផលនៃការខិតខំធ្វើការងារ និងទេពកោសល្យរបស់ពួកគេ ។ នេះមានន័យថាមនុស្សម្នាក់គួរទទួលបានការងារដោយផ្អែកលើបំណិន និងបទពិសោធន៍របស់ពួកគេ មិនមែនដោយសារភេទ ទ្រព្យសម្បត្តិ ឬប្រវត្តិរបស់ពួកគេទេ ។

នៅពេលអង្គការមួយត្រូវការជ្រើសរើសបុគ្គលិកបំពេញការងារមួយ ច្បាប់គាំទ្រថាពួកគេជ្រើសរើសមនុស្សដែលមានបំណិន និងបទពិសោធន៍ល្អបំផុតសម្រាប់ការងារនោះ ។

ជនចំណាកស្រុកថ្មីជាច្រើននៅក្នុងប្រទេសអូស្ត្រាលីបានក្លាយជាអ្នកដឹកនាំនៅក្នុងអាជីវកម្ម វិជ្ជាជីវៈរបស់ពួកគេ សិល្បៈ សេវាសាធារណៈ និងកីឡាតាមរយៈការខិតខំធ្វើការងារ និងភាពប៉ិនប្រសប់របស់ពួកគេ ។

ការគោរពគ្នាទៅវិញទៅមក និងការអធ្យាស្រ័យចំពោះអ្នកដទៃ

នៅក្នុងប្រទេសអូស្ត្រាលី បុគ្គលទាំងអស់ត្រូវគោរពសេរីភាព និងភាពថ្លៃថ្នូររបស់អ្នកដទៃ ហើយនិងមតិយោបល់ និងជម្រើសរបស់ពួកគេ ។

វាជាអំពើប្រឆាំងនឹងច្បាប់ដែលប្រព្រឹត្តិអំពើហិង្សាចំពោះមនុស្សម្នាក់ផ្សេងទៀត ។ អំពើហិង្សាប្រភេទណាក៏ដោយដោយរួមមានការបំពានលើពាក្យសម្ដី និងលើរាយកាយគឺជាអំពើខុសច្បាប់ ។ ប្រជាជនអូស្ត្រាលីមានជំនឿទៅលើការខ្វែងគំនិតគ្នាដោយសន្តិវិធី ហើយជាពិសេសបំផុតគឺសិទ្ធិទទួលបានសុវត្ថិភាព និងគ្មានអំពើហិង្សា និងការគំរាមកំហែង ។

នៅក្នុងប្រទេសអូស្ត្រាលី មានច្បាប់តឹងតែងណាស់ទាក់ទងនឹងអាយុដែលអាចផ្តល់ការយល់ព្រមរួមផ្លូវភេទដែលមានអាយុ16 ឬ 17 ឆ្នាំ ដោយអាស្រ័យទៅលើរដ្ឋ ឬដែនដីដែលលោកអ្នករស់នៅ ។ ឧទាហរណ៍ នៅក្នុងប្រទេសអូស្ត្រាលី បុរសដែលមានអាយុ 20ឆ្នាំ មិនអាចមានទំនាក់ទំនងផ្លូវភេទជាមួយក្មេងស្រីដែលមានអាយុ 15 ឆ្នាំបានឡើយ ពីព្រោះទង្វើនេះគឺប្រឆាំងនឹង ច្បាប់នៅក្នុងរដ្ឋ និងដែនដីអូស្ត្រាលីទាំងអស់ ។

នៅប្រទេសអូស្ត្រាលី សកម្មភាពស្របច្បាប់របស់ប៉ូលីសគួរទទួលបានការគាំទ្រ ។ លោកអ្នកគួរគោរពសំណើស្របច្បាប់ពីប៉ូលីស ពីព្រោះជនជាតិអូស្ត្រាលីទាំងអស់ប្តេជ្ញាអនុវត្តតាមច្បាប់ ។

ប្រទេសអូស្ត្រាលីឱ្យតម្លៃទៅលើគោលការណ៍នៃការគោរព និងការអធ្យាស្រ័យគ្នា ទៅវិញទៅមក ។ នេះមានន័យថាការស្តាប់អ្នកដទៃ និងការគោរពទស្សនៈ និងមតិរបស់ពួកគេ ទោះជា នៅពេលទស្សនៈ និងមតិទាំងនោះខុសពីរបស់លោកអ្នកផ្ទាល់ក៏ដោយ ។ មនុស្សគួរអធ្យាស្រ័យគ្នាទៅវិញទៅមកក្នុងខណៈដែលពួកគេមានការខ្វែងគំនិតគ្នា ។

ការប្រកាន់ពូជសាសន៍មិនអាចមាននៅប្រទេសអូស្ត្រាលី ។ នេះរាប់បញ្ចូលទាំងការបង្កើត ឬចែករំលែកសម្ភារៈដែលវាយប្រហារលើជាតិសាសន៍នៅតាមអ៊ិនថឺណិត ឬក៏ការបោះពុម្ពផ្សព្វផ្សាយផ្សេងទៀត ហើយនិងការបញ្ចេញយោបល់បែបបំពានលើជាតិសាសន៍ នៅកន្លែងសាធារណៈ ឬនៅពិធីប្រកួតកីឡា ។

សហគមន៍របស់យើង

ការធ្វើវិភាគទាន

សញ្ជាតិអូស្ត្រាលីផ្តល់ជូនលោកអ្នកនូវឱកាសដើម្បីចូលរួមយ៉ាងពេញលេញនៅក្នុងជីវភាពប្រជាជាតិ និងសហគមន៍របស់យើង ។ នេះមានន័យថាលោកអ្នកបានប្រុងប្រៀបខ្លួនជាស្រេចដើម្បីបំពេញនូវការទទួលខុសត្រូវរបស់លោកអ្នក ក្នុងនាមជាពលរដ្ឋអូស្ត្រាលីម្នាក់ ។ ជនជាតិអូស្ត្រាលីរំពឹងឱ្យជនគ្រប់រូបរស់នៅក្នុងប្រទេសអូស្ត្រាលីចូលរួមនៅក្នុងសង្គមរបស់យើង និងធ្វើវិភាគទានដល់សហគមន៍របស់យើង ។ ជនគ្រប់រូបមានការទទួលខុសត្រូវចំពោះការគាំទ្រខ្លួនឯង និងគ្រួសាររបស់ពួកគេ នៅពេលពួកគេមានសមត្ថភាពធ្វើបានដូច្នេះ ។

សេចក្តីមេត្តាចំពោះអ្នកខ្វះខាត

មិត្តភាពស្មើគ្នា និងស្មោះត្រង់ (mateship) គឺជាគុណតម្លៃរបស់ប្រទេសអូស្ត្រាលី ។ យើងជួយគ្នាទៅវិញទៅមកនៅពេលខ្វះខាត ។ ឧទាហរណ៍ នេះអាចមានន័យថា ការយកម្ហូបអាហារទៅជូនមនុស្សចាស់នៅជិតខាង បើកឡានជូនមិត្តភក្តិទៅជួបវេជ្ជបណ្ឌិត ឬទៅសាកសួរសុខទុក្ខអ្នកមានជំងឺ ទន់ខ្សោយ ឬនៅឯកកោ ។

នៅក្នុងស្មារតីនៃមិត្តភាពស្មើគ្នា និងស្មោះត្រង់ (mateship) ប្រទេសអូស្ត្រាលីមានប្រពៃណីដ៏រឹងមាំមួយក្នុងការផ្តល់សេវាដល់សហគមន៍ និងការស្ម័គ្រចិត្ត—យកចិត្តទុកដាក់មើលថែគ្នាទៅវិញទៅមក និងពង្រឹងសហគមន៍ ។ ការស្ម័គ្រចិត្តគឺជាឱកាសដ៏សំខាន់មួយដើម្បីចែករំលែកចំណេះដឹង រៀនបំណិនថ្មីៗ និងបង្កើនការបញ្ជ្រាបខ្លួនចូលទៅក្នុងសហគមន៍អូស្ត្រាលីឱ្យបានលឿន ហើយដឹងថា សហគមន៍អូស្ត្រាលីជាកម្មសិទ្ធិរបស់ខ្លួន ។ មានឱកាសជាច្រើនសម្រាប់លោកអ្នកដើម្បីធ្វើការស្ម័គ្រចិត្តនៅក្នុងប្រទេសអូស្ត្រាលី ។

ភាសាអង់គ្លេសជាភាសាជាតិ

សង្គមអូស្ត្រាលីឱ្យតម្លៃលើភាសាអង់គ្លេសជាភាសាជាតិរបស់ប្រទេសអូស្ត្រាលី ហើយជា ធាតុបង្រួបបង្រួមដ៏សំខាន់មួយនៃសង្គម ។ មនុស្សដែលរស់នៅក្នុងប្រទេសអូស្ត្រាលីគួរខិតខំព្យាយាមរៀនភាសាអង់គ្លេស ។

វាមានសារៈសំខាន់ត្រូវតែរៀនភាសាអង់គ្លេស ពីព្រោះវាជួយឱ្យទទួលបានការអប់រំ ការងារ និងជួយឱ្យបញ្ជ្រាបខ្លួនចូលទៅក្នុងសហគមន៍បានប្រសើរជាង ។ វាមានសារៈសំខាន់ណាស់សម្រាប់ការចូលរួមក្នុងសេដ្ឋកិច្ច និងភាពជិតស្និតនៅក្នុងសង្គម ។ អ្នកដាក់ពាក្យសុំចូលសញ្ជាតិអូស្ត្រាលីត្រូវតែខិតខំប្រឹងប្រែងឱ្យសមហេតុផលដើម្បីរៀនភាសាអង់គ្លេស ប្រសិនបើភាសាអង់គ្លេសមិនមែនជាភាសាកំណើតរបស់ពួកគេទេ ។

ការជួយរក្សាសង្គមរបស់យើងឱ្យមានសុវត្ថិភាព

នៅក្នុងប្រទេសអូស្ត្រាលី យើងម្នាក់ៗមានការទទួលខុសត្រូវជួយការពារសង្គមអូស្ត្រាលី ។ ឧទាហរណ៍ ប្រសិនបើមនុស្សនៅក្នុងប្រទេសអូស្ត្រាលីមានការសង្ស័យថាមិត្តភក្តិ ឬអ្នកជិតខាងរបស់ពួកគេអាចកំពុងរៀបចំផែនការប្រព្រឹត្តិបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ពួកគេគួររាយការណ៍រឿងនេះទៅអាជ្ញាធររដ្ឋាភិបាលអូស្ត្រាលីឱ្យបានឆាប់ដែលអាចធ្វើទៅបាន ។ តាមវិធីនេះ យើងអាចជួយការពារសុវត្ថិភាពនៃសហគមន៍របស់យើងបាន ។

ស្រដៀងគ្នានេះដែរ ប្រសិនបើជនម្នាក់នៅក្នុងប្រទេសអូស្ត្រាលីឃើញ ឬដឹងពីការបំពានលើកុមារម្នាក់ ពួកគេគួររាយការណ៍រឿងនេះទៅប៉ូលីសដើម្បីឱ្យ ធ្វើការស៊ើបអង្កេត ។

ការបំពានតាមអនឡាញមិនអាចទទួលយកបានទេនៅប្រទេសអូស្ត្រាលី ។ នេះជួនកាលគេហៅថាការបំពានតាមប្រព័ន្ធបច្ចេកវិទ្យា ។ ឧទាហរណ៍មានជាអាទិដូចជាការចែករំលែករូបថត ឬវីដេអូរួមភេទដោយគ្មានការយល់ព្រម ការតាមឈ្លបមើលមនុស្សតាមអនឡាញ ឬក៏ការបញ្ចេញយោបល់ដោយបំពានលើជាតិសាសន៍អំពីមនុស្សម្នាក់តាមអនឡាញ ។ មានទម្រង់នៃការបំពានតាមប្រព័ន្ធបច្ចេកវិទ្យាជាច្រើនគឺខុសច្បាប់នៅប្រទេសអូស្ត្រាលី ។

ភក្តីភាពចំពោះប្រទេសអូស្ត្រាលី

នៅក្នុងការធ្វើសច្ចាប្រណិធានក្នុងពិធីចូលសញ្ជាតិ ពលរដ្ឋអូស្ត្រាលីធ្វើសច្ចាប្រណិធាន ភក្តីភាពរបស់ពួកគេចំពោះប្រទេសអូស្ត្រាលី និងប្រជាជនអូស្ត្រាលី ។ ពលរដ្ឋអូស្ត្រាលីក៏អាចកាន់សញ្ជាតិនៃប្រទេសមួយទៀត ឬប្រទេសនានាបានដែរ ប្រសិនបើច្បាប់នៃប្រទេសទាំងនោះអនុញ្ញាតឱ្យ ។ នេះគេស្គាល់ថាជាការមានសញ្ជាតិពីរ ឬសញ្ជាតិច្រើន ។ ក៏ប៉ុន្តែ ទោះជាជនណាម្នាក់ក៏ជាពលរដ្ឋនៃប្រទេសមួយផ្សេងទៀតក៏ដោយ ពលរដ្ឋអូស្ត្រាលីនៅក្នុងប្រទេសអូស្ត្រាលីត្រូវតែគោរពតាមច្បាប់ប្រទេសអូស្ត្រាលីទាំងអស់នៅគ្រប់ពេលវេលា ។ ពលរដ្ឋអូស្ត្រាលីត្រូវតែអនុវត្តតាមច្បាប់អូស្ត្រាលីមួយចំនួន ទោះបីជាពួកគេនៅក្រៅប្រទេសក៏ដោយ ។ ឧទាហរណ៍ វាជាអំពើខុសច្បាប់សម្រាប់ជនជាតិអូស្ត្រាលីជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពរួមភេទណាមួយនៅក្នុងប្រទេសអូស្ត្រាលី ឬនៅក្រៅប្រទេសជាមួយកុមារដែលមានអាយុក្រោម 16ឆ្នាំ ។

សង្គមអូស្ត្រាលីគឺផ្អែកទៅលើកាតព្វកិច្ចរួមរបស់យើងគឺមិនបំផ្លាញផលប្រយោជន៍ និងសន្តិសុខរបស់ប្រទេសអូស្ត្រាលីទេ ។ ឧទាហរណ៍ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីចែករំលែករឿងសម្ងាត់របស់រដ្ឋាភិបាលផ្លូវការនឹងកំពុងតែបំផ្លាញផលប្រយោជន៍ប្រទេសអូស្ត្រាលីហើយ ។ ស្រដៀងគ្នានេះដែរ ការបង្កើនការមិនទុកចិត្តគ្នានៅក្នុង និងការភ័យខ្លាចនៃសហគមន៍ ជាតិសាសន៍មួយនឹងធ្វើឱ្យខូចខាងដល់ទំនាក់ទំនងនៅក្នុងសហគមន៍អូស្ត្រាលី ។

នៅក្នុងប្រទេសអូស្ត្រាលី យើងរួមសហការគ្នានៅក្នុងពេលមានវិបត្តិ និងថែរក្សាគ្នាទៅវិញទៅមកនៅក្នុងគ្រាល្អ និងអាក្រក់ ។ នៅក្នុងរដូវភ្លើងឆេះព្រៃដ៏សាហាវនៅអូស្ត្រាលីក្នុងឆ្នាំ2019-20 ដែលបានបង្កការខូចខាចយ៉ាងធ្ងន់ធ្ងរដល់ជីវិត ផ្ទះសម្បែង និងសត្វព្រៃ ហើយការបំផ្លាញបរិស្ថាន សហគមន៍ពហុវប្បធម៌ជាច្រើនបានធ្វើការប្រមូលលុយ សម្លៀកបំពាក់ និងអំណោយអាហារដើម្បីជួយដល់មនុស្សដែលរងគ្រោះដោយសារភ្លើងឆេះព្រៃ ។ ឧទាហរណ៍ សមាជិកសហគមន៍ចិន វៀតណាម និងកម្ពុជានៅក្នុងរដ្ឋវិចតូរីយ៉ាបានប្រមូលអំណោយនៅតាមមជ្ឈមណ្ឌលលក់ដូរ និងបានរៃអង្គាសប្រាក់តាមពិធីក្រុមសហគមន៍តាមមូលដ្ឋាន និងសមាជិកសហគមន៍ស៊ីកបានបរិច្ចាកទឹករាប់ពាន់ដបទៅដល់សហគមន៍ និងក្រុមអគ្គីភ័យនៅរដ្ឋឃ្វីនស្លែនដ៍ ។

សេចក្តីសន្និដ្ឋាន

ស្ថាប័នលទ្ធិប្រជាធិបតេយ្យ និងគុណតម្លៃរួមរបស់ប្រទេសអូស្ត្រាលីរបស់យើងបានបង្កើតសង្គមដែលមានសន្តិភាព និងស្ថេរភាពរបស់យើង ។

យើងមានវប្បធម៌សម្បូរបែប និងប្លែកខុសពីគេដើម្បីចែករំលែក ។ ក្នុងនាមជាពលរដ្ឋអូស្ត្រាលីមួយរូប លោកអ្នកនឹងក្លាយជាផ្នែកមួយនៃខ្សែរឿងរបស់ប្រជាជាតិយើង ហើយនិងផ្តល់វិភាគទានដល់អនាគតរបស់យើង ។ ប្រទេសអូស្ត្រាលីសូមស្វាគមន៍លោកអ្នក ។ ភាពជាពលរដ្ឋគឺជាចំណងរួមរបស់យើង ។

សន្ទានុក្រមសម្រាប់ផ្នែកដែលអាចយកមកប្រឡង

ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្ត្រេត (Torres Strait)

ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្ត្រេត (Torres Strait) គឺម្ចាស់ស្រុកនៃទឹកដីប្រទេសអូស្ត្រាលី ។
ជនជាតិដើមអាបូរីជីនី និងជនជាតិដើមរស់នៅតាមកោះថ័រិសស្ត្រេត (Torres Strait) មានចំនួនប្រហែលជា បីភាគរយនៃចំនួនប្រជាជនអូស្ត្រាលីទាំងអស់ ។

គណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី

គណៈកម្មការឯករាជ្យដែលស៊ើបអង្កេតទៅលើបណ្តឹងស្តីពីការរើសអើង និងការរំលោភសិទ្ធិមនុស្ស ។
ឧប្បត្តិហេតុនៃការប្រកាន់ពូជសាសន៍អាចរាយការណ៍ទៅគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី ។

សេវាសាធារណៈប្រទេសអូស្ត្រាលី

ក្រសួងរដ្ឋាភិបាល និងមនុស្សដែលធ្វើការងារឱ្យក្រសួង
Paul បានការងារធ្វើនៅក្នុងសេវាសាធារណៈប្រទេសអូស្ត្រាលីជាបុគ្គលិកនៃក្រសួងផ្តល់សេវាអូស្ត្រាលី ។

ការបះបោររបស់ពលរដ្ឋ

បាតុកម្ម និងកុបកម្មដោយមានចំនួនមនុស្សច្រើនជាងធម្មតាដែលតវ៉ាប្រឆាំងនឹងការសម្រេច ឬគោលនយោបាយរបស់រដ្ឋាភិបាល ។
មានការបះបោររបស់ពលរដ្ឋនៅពេលរដ្ឋាភិបាលបានអនុម័តច្បាប់ដែលគ្មានប្រជាប្រិយភាព ។

គណបក្សចម្រុះ

ការចូលរួមនៃគណបក្សនយោបាយចំនួនពីរ ឬច្រើនជាង ជាធម្មតាដើម្បីបង្កើតរដ្ឋាភិបាល ឬក៏គណបក្សប្រឆាំង ។
បន្ទាប់ពីការបោះឆ្នោតមក គ្មានគណបក្សណាមួយទទួលបានសម្លេងគាំទ្រច្រើននៅក្នុងសភាតំណាងរាស្ត្រ ដូច្នេះគណបក្សចំនួនពីរដែលមានគំនិតស្រដៀងគ្នាបានរួបរួមគ្នាបង្កើតគណបក្សចម្រុះមួយ ។

គណៈកម្មការ

ក្រុមមនុស្សមួយដែលមានការទទួលខុសត្រូវជាផ្លូវការ
គណៈកម្មការឯករាជ្យរៀបចំការបោះឆ្នោត ។

រដ្ឋធម្មនុញ្ញ

ច្បាប់កំពូលនៃប្រទេសអូស្ត្រាលីដែលរដ្ឋាភិបាលត្រូវតែគោរពតាម ។
រដ្ឋធម្មនុញ្ញចែងពីអំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ

របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ

ប្រទេសមួយដែលក្នុងនោះមានព្រះមហាក្សត្រ ឬព្រះមហាក្សត្រយានីធ្វើជាប្រមុខរដ្ឋ ដែលអំណាចរបស់ព្រះអង្គត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញ
រដ្ឋធម្មនុញ្ញរបស់យើងបានបង្កើតកុំម៉ន់វេលអូស្ត្រាលីជារបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដោយមានព្រះមហាក្សត្រ ឬព្រះមហាក្សត្រយានីនៃចក្រភពអង់គ្លេសធ្វើជាប្រមុខរដ្ឋរបស់យើង ។

តុលាការ

ទីកន្លែងដែលបណ្តឹងតាមផ្លូវច្បាប់ត្រូវបានជំនុំជម្រះដោយចៅក្រម ឬចៅក្រមថ្នាក់ក្រោម
នៅពេលមនុស្សបំពានច្បាប់ ពួកគេអាចត្រូវឡើងតុលាការ ។

ការជំនុំជម្រះក្តីព្រហ្មទណ្ឌ

នៅក្នុងសវនាការស្តាប់ការពិតដោយតុលាការដើម្បីសម្រេចថាតើជនណាម្នាក់មានទោស ឬក៏គ្មានទោសពីបទឧក្រិដ្ឋមួយ ។
បន្ទាប់ពីការជំនុំជម្រះក្តីព្រហ្មទណ្ឌ ចោរប្លន់ធនាគារត្រូវបានបញ្ជូនទៅពន្ធនាគារ ។

ការបំពានតាមប្រព័ន្ធបច្ចេកវិទ្យា

អាកប្បកិរិយាដែលប្រើបច្ចេកវិទ្យាដើម្បីគម្រាម បំភ័យ រុកគួន ឬក៏ធ្វើឱ្យអ្នកណាម្នាក់អាម៉ាស់មុខដោយមានចេតនាធ្វើឱ្យពួកគេឈឺចាប់ ។
ការបំពានតាមប្រព័ន្ធបច្ចេកវិទ្យាជាច្រើនប្រភេទគឺប្រឆាំងនឹងច្បាប់នៅប្រទេសអូស្ត្រាលី ហើយគួរត្រូវរាយការណ៍ទៅប៉ូលីស ហើយនិងសេវាអនឡាញដូចជាវេទិការបណ្តាញផ្សព្វផ្សាយព័ត៌មានសង្គមដែលមានរឿងនេះកើតឡើង ។

លទ្ធិប្រជាធិបតេយ្យ

រដ្ឋាភិបាលដែលជ្រើសតាំងដោយប្រជាជនតាមរយៈតំណាងដែលជាប់ឆ្នោត ។
Grace មានក្ដីរីករាយរស់នៅក្នុងលទ្ធិប្រជាធិបតេយ្យដែលនាងអាចបោះឆ្នោតជ្រើសតាំងតំណាងនៅក្នុងសភារបស់នាង ។

អំពើហិង្សានៅក្នុងផ្ទះ និងក្នុងគ្រួសារ

អាកប្បកិរិយា ឬការគម្រាមកំហែងដែលមានបំណងត្រួតត្រាដៃគូដោយបង្កការភ័យខ្លាច ឬក៏គម្រាមកំហែងសុវត្ថិភាពពួកគេ ។ អំពើហិង្សានៅក្នុងផ្ទះ និងក្នុងគ្រួសារគឺជាអំពើមិនអាចទទួលយកបាន និងប្រឆាំងនឹងច្បាប់ ។
អំពើហិង្សានៅក្នុងផ្ទះ និងក្នុងគ្រួសារគឺជាអំពើប្រឆាំងនឹងច្បាប់នៅប្រទេសអូស្ត្រាលី ហើយគួរត្រូវរាយការណ៍ទៅប៉ូលីស ។

ការជួញដូរគ្រឿងញៀន

ការកាន់ ឬទិញគ្រឿងញៀនទៅលក់ដោយខុសច្បាប់ ។
Jess ត្រូវបានបញ្ជូនទៅពន្ធនាគារពីបទជួញដូរគ្រឿងញៀន ។

ការបោះឆ្នោត

ដំណើការដែលតាមរយៈនេះ ពលរដ្ឋជ្រើសរើសមនុស្សឱ្យធ្វើជាតំណាងពួកគេនៅក្នុងសភា
ជនជាតិអូស្ត្រាលីដែលមានអាយុ 18 ឆ្នាំឡើងទៅត្រូវបោះឆ្នោតនៅក្នុងការបោះឆ្នោត ។

បញ្ជីឈ្មោះបោះឆ្នោត

បញ្ជីរាយមនុស្សដែលបានចុះឈ្មោះដើម្បីបោះឆ្នោតនៅក្នុងការបោះឆ្នោត ឬការធ្វើប្រជាមតិ
នៅពេល Jan បានមកដល់មជ្ឈមណ្ឌលបោះឆ្នោត មន្ត្រីបោះឆ្នោតបានមើលរកឈ្មោះរបស់នាងនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ។

មណ្ឌលបោះឆ្នោត

ស្រុកនានាដែលមានអ្នកបោះឆ្នោតដែលបោះឆ្នោតជ្រើសតាំងអ្នកនយោបាយនៅក្នុងសភាតំណាងរាស្ត្រ ។
មណ្ឌលបោះឆ្នោតត្រូវបានគេហៅថាស្រុក ខណ្ឌបោះឆ្នោត ឬកៅអីបោះឆ្នោត ។

សមភាព

ដូចគ្នានៅក្នុងឋានៈ
ជនជាតិអូស្ត្រាលីជឿទៅលើសមភាពរបស់មនុស្សទាំងអស់ ។

ប្រតិបត្តិច្បាប់

ធានាថាមនុស្សអនុវត្តតាមច្បាប់
ប៉ូលីសប្រតិបត្តិច្បាប់ និងរក្សាសន្តិភាព ។

អំណាចនីតិប្រតិបត្តិ

អំណាច និងអាជ្ញាធរគ្រប់គ្រងច្បាប់ ជាអំណាចមួយនៃអំណាចទាំងបីនៅក្រោមរដ្ឋធម្មនុញ្ញនៃប្រទេសអូស្ត្រាលី
រដ្ឋមន្ត្រីរដ្ឋាភិបាលអូស្ត្រាលី និងអគ្គទេសាភិបាលមានអំណាចនីតិប្រតិបត្តិដើម្បីគ្រប់គ្រងច្បាប់ដែលបានធ្វើដោយសភាអូស្ត្រាលី ។

ឱកាសដូចគ្នា

ជនគ្រប់រូបដោយមិនគិតពីប្រវត្តិរបស់ពួកគេទទួលបានឱកាសស្មើៗគ្នាដើម្បីសម្រេចភាពជោគជ័យនៅក្នុងជីវិត ។
នៅក្នុងប្រទេសអូស្ត្រាលី យើងជឿថាមនុស្សគ្រប់រូបគួរទទួលបាន 'ឱកាសដូចគ្នា - fair go' ។

សហព័ន្ធ

ការបង្រួបបង្រួមអាណានិគមនានាចូលជាប្រជាជាតិតែមួយ ដោយអាណានិគមទាំងនេះរក្សាអំណាចជាក់លាក់ខ្លះ
នៅឆ្នាំ1901 អាណានិគមនានាបានរួបរួមគ្នាទៅជាសហព័ន្ធដែលគេហៅថា កុំម៉ន់វែលអូស្ត្រាលី ។

កងនាវាទីមួយ

ក្រុមនាវាដែលមានសំពៅទាំង 11គ្រឿងដែលបានចាកចេញពីចក្រភពអង់គ្លេសក្រោមការដឹកនាំរបស់លោកនាយនាវាឈ្មោះ Arthur Phillip ដើម្បីបង្កើតការតាំងលំនៅដ្ឋានរបស់អ្នកទោសនៅក្នុងរដ្ឋញ៉ូវសៅវែលស៍ ។
កងនាវាទីមួយបានចូលចតនៅឆកសមុទ្រទីក្រុងស៊ីដនី នៅថ្ងៃទី26 ខែមករា ឆ្នាំ1788 ។

និមិត្តសញ្ញាផ្កា

ផ្កាតំណាងជាតិ
និមិត្តសញ្ញាផ្ការបស់ប្រទេសអូស្ត្រាលីគឺផ្ការ៉ាតថលពណ៌មាស ។

អាពាហ៍ពិពាហ៍ដោយបង្ខំ

អាពាហ៍ពិពាហ៍ដែលមានមនុស្សម្នាក់ ឬគូទាំងពីនាក់គ្មានជម្រើសដោយសេរី ។
នាងមិនដែលសប្បាយចិត្តនឹងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់នាងទេ ហើយជានិច្ចកាល នាងចង់ចាកចេញពីអាពាហ៍ពិពាហ៍របៀបនេះ ។

ចាប់ពីពេលនេះតទៅមុខ

ចាប់ពីពេលនេះទៅ និងនៅពេលអនាគត

នៅក្នុងពិធីចូលសញ្ជាតិ លោកអ្នកធ្វើការសន្យាថាមានភក្តីភាពចំពោះប្រទេសអូស្ត្រាលី ចាប់ពីពេលនេះតទៅមុខ ។

រូបតំណាងល្បីល្បាញ

រូបភាពល្បីល្បាញ

រោងល្ខោនអូប៉េរ៉ា (Opera House)

នៃជនជាតិដើម

ជនជាតិដើមអាបូរីជីនី និង/ឬជនជាតិដើមរស់នៅតាមកោះច់រិសស្រ្តេត (Torres Strait)

ជនជាតិដើមប្រទេសអូស្ត្រាលីគឺជាមនុស្សដំបូងគេនៃប្រទេសនេះ ។

ការបញ្ច្រាបខ្លួន

ដំណើរការសម្របខ្លួនរបស់ជនចំណាកស្រុកដើម្បីឱ្យពួកគេអាចចូលរួមនៅក្នុង និងផ្តល់វិភាគទានដល់សង្គមដែលកំពុងរីវឌ្ឍន៍ និងសង្គមថ្មីរបស់ពួកគេ ។

ជាបណ្តើរៗ ជនចំណាកស្រុកបានទទួលផលប្រយោជន៍ពីការបញ្ច្រាបខ្លួនចូលទៅក្នុងប្រទេសអូស្ត្រាលី និងសហគមន៍មូលដ្ឋាន ។

អំណាចតុលាការ

អំណាច និងអាជ្ញាធរដើម្បីបកស្រាយ និងអនុវត្តច្បាប់ ជាអំណាចមួយនៃអំណាចទាំងបីនៅក្រោមរដ្ឋធម្មនុញ្ញប្រទេសអូស្ត្រាលី ។

តុលាការនៅក្នុងប្រទេសអូស្ត្រាលីមានអំណាចតុលាការ ។

អំណាចនីតិបញ្ញត្តិ

អំណាច និងអាជ្ញាធរដើម្បីធ្វើ និងកែប្រែច្បាប់ ជាអំណាចមួយនៃអំណាចទាំងបីនៅក្រោមរដ្ឋធម្មនុញ្ញប្រទេសអូស្ត្រាលី ។

នៅក្រោមរដ្ឋធម្មនុញ្ញ សភាមានអំណាចនីតិបញ្ញត្តិ ។

សេរីភាព

សេរីភាពផ្ទាល់ខ្លួន និងឯករាជ្យភាព

នៅក្នុងសង្គមលទ្ធិប្រជាធិបតេយ្យរបស់យើង មនុស្សមានសេរីភាពក្នុងការនិយាយស្តី សេរីភាពក្នុងការសម្តែងមតិ សេរីភាពខាងជំនឿសាសនា និងសេរីភាពក្នុងការបង្កើតសមាគម ។ យើងឱ្យតម្លៃទៅលើសេរីភាពទាំងនេះ ។

ចៅក្រមថ្នាក់ក្រោម

ចៅក្រមនៃតុលាការថ្នាក់ក្រោម

តុលាការថ្នាក់ក្រោមបានរកឃើញថាចោរមានទោស ហើយបញ្ជូនគាត់ទៅពន្ធនាគារ ។

មិត្តភាពស្មើគ្នា និងស្មោះត្រង់

ការជួយ និងទទួលជំនួយពីអ្នកដទៃ ជាពិសេសក្នុងគ្រាលំបាក

នៅពេលឡានខ្ញុំខូច អ្នកបើកបរម្នាក់ទៀតបានជួយរុញឡាននៅក្នុងស្មារតីមិត្តភាពស្មើគ្នា និងស្មោះត្រង់ ។

ភ្លេងជាតិ

ចម្រៀងជាតិ

ភ្លេងជាតិរបស់ប្រទេសអូស្ត្រាលីគឺ 'Advance Australia Fair' ។

លទ្ធិប្រជាធិបតេយ្យតាមបែបសភា

ប្រព័ន្ធរដ្ឋាភិបាលដែលមានមូលដ្ឋានលើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ យ៉ាងទៀងទាត់ដោយពលរដ្ឋ

នៅក្នុងលទ្ធិប្រជាធិបតេយ្យតាមបែបសភា ប្រជាជនបោះឆ្នោតឱ្យតំណាងរបស់ពួកគេ ។

គណបក្សនយោបាយ

ក្រុមមនុស្សដែលមានគំនិតស្រដៀងគ្នាស្តីពីវិធីដែលគួរគ្រប់គ្រងប្រទេស និងជាធម្មតា ប្រឹងប្រែងឱ្យបានជាប់ឆ្នោត ។

សមាជិកគណបក្សនយោបាយជួបជុំគ្នាជាទៀតទាត់ ឧទាហរណ៍ ដើម្បីពិភាក្សាអំពីការកែលម្អការដឹកជញ្ជូនសាធារណៈ ។

ការប្រកាន់ពូជសាសន៍

ភាពលំអៀង ការរើសអើង ការរុកគួន ឬក៏ការស្អប់ខ្ពើមដែលសម្តៅទៅកាន់អ្នកណាម្នាក់ដោយសារជាតិសាសន៍ ពណ៌សម្បុរ ដើមកំណើតជាតិ និងសញ្ជាតិរបស់ពួកគេ ។

ការប្រកាន់ពូជសាសន៍គឺប្រឆាំងនឹងច្បាប់នៅក្នុងប្រទេសអូស្ត្រាលី ហើយគួរត្រូវរាយការណ៍ទៅប៉ូលីស ។ បណ្តឹងក៏អាចធ្វើទៅគណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលីបានដែរ ។

ប្រជាមតិ

ការបោះឆ្នោតដោយអ្នកបោះឆ្នោតទាំងអស់ទៅលើការកែប្រែរដ្ឋធម្មនុញ្ញប្រទេសអូស្ត្រាលីដែលបានស្នើឡើង

នៅក្នុងប្រជាមតិឆ្នាំ1967 ប្រជាជនបានបោះឆ្នោតដើម្បីរាប់ជនជាតិដើមអាបូរីជីនីទៅក្នុងជំរឿនប្រជាជន ។

តំណាង

មនុស្សដែលធ្វើសកម្មភាព និងនិយាយជំនួសអ្នកដទៃ
តំណាងក្រុមប្រឹក្សាមូលដ្ឋានចូលចិត្តគំនិតរបស់ខ្ញុំ និងបានបង្ហាញវានៅក្នុងអង្គប្រជុំក្រុមប្រឹក្សា ។

ការគោរព

បង្ហាញពីការចាត់ទុកជនណាមួយជាមនុស្សម្នាក់ ឬក៏ការគិតពិចារណ៍លើសេចក្តីសម្រេច ដែលពួកគេបានធ្វើ ។
Emily មានសេចក្តីរីករាយដែលគ្រួសាររបស់នាងបានគោរពសេចក្តីសម្រេចរបស់នាងចង់ ក្លាយជាពុទ្ធសាសនិកម្នាក់ ។

នីតិរដ្ឋ

មនុស្សទាំងអស់ដោយរួមទាំងពលរដ្ឋ និងរដ្ឋាភិបាលត្រូវតែគោរពតាមច្បាប់ ។
មនុស្សគ្រប់រូបនៅក្នុងប្រទេសអូស្ត្រាលីដោយរួមទាំងនាយករដ្ឋមន្ត្រីត្រូវតែគោរពច្បាប់ប្រទេសអូស្ត្រាលីទាំងអស់នៅក្រោមនីតិរដ្ឋ ។

ក្រសួងផ្តល់សេវាអូស្ត្រាលី

ទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីដែលផ្តល់សេវាសុខាភិបាល សេវាសង្គមកិច្ច និងប្រាក់ឧបត្ថម្ភសង្គមកិច្ចតាមរយៈ Medicare Centrelink និង Child Support ។
ក្រសួងផ្តល់សេវាអូស្ត្រាលីផ្តល់ប្រាក់ឧបត្ថម្ភតាមរយៈ Centrelink និងសេវាផ្សេងៗទៀត ។

សន្លឹកឆ្នោតសម្ងាត់

ប្រព័ន្ធនៃការបោះឆ្នោតដែលប្រជាជនបោះឆ្នោតដោយឯកជន ដើម្បីកុំឱ្យមានជនណាម្នាក់មានឥទ្ធិពល ឬដាក់សម្ពាធទៅលើពួកគេឱ្យបោះឆ្នោតតាមវិធីណាមួយបាន ។
នៅក្នុងសន្លឹកឆ្នោតសម្ងាត់ គ្មានជនណាម្នាក់មើលឃើញទេ នៅពេលលោកអ្នកគូសសន្លឹកឆ្នោតលោកអ្នក ។

មិនពាក់ព័ន្ធនឹងសាសនា

ដាច់ដោយឡែកពីសាសនា
នៅក្នុងសង្គមដែលមិនពាក់ព័ន្ធនឹងសាសនា គ្មានសាសនាផ្លូវការទេ ។

ដែលមានស្វ័យភាព ឬភាពម្ចាស់ការលើខ្លួនឯង

អាចផ្គត់ផ្គង់តម្រូវការខ្លួនផ្ទាល់របស់លោកអ្នកបាន ដោយគ្មានជំនួយពីអ្នកដទៃ
ការមានការងារធ្វើមានន័យថាគាត់អាចទិញអាហារផ្ទាល់ខ្លួនរបស់គាត់ និងបង់ថ្លៃជួលផ្ទះផ្ទាល់ខ្លួនរបស់គាត់បាន ។ គាត់មានភាពម្ចាស់ការលើខ្លួនឯង

បង្កើត

កសាង បង្កើត ចាប់ផ្តើម
លោកទេសាភិបាល Phillip បានបង្កើតអាណានិគមទីមួយនៅក្នុងរដ្ឋញ៉ូវសៅវែលស៍ ។

ស្រុក

តំបន់រដ្ឋាភិបាលមូលដ្ឋាន
ផ្លូវថ្នល់នៅក្នុងស្រុកខ្ញុំមានសុវត្ថិភាពណាស់ ។

សន្តិសុខសង្គម

ប្រាក់សោធននិវត្ត និងប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាលដើម្បីជួយអ្នកគ្មានការងារធ្វើ ជនពិការ មនុស្សចាស់ និងអ្នកដទៃទៀតដែលខ្វះខាត ។
នៅពេល Trang បាត់បង់ការងាររបស់នាង នាងបានដាក់ពាក្យសុំប្រាក់ឧបត្ថម្ភសន្តិសុខសង្គម ។

ក្រសួងពន្ធដារអូស្ត្រាលី (ATO)

ទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីដែលគ្រប់គ្រងប្រព័ន្ធពន្ធដារ និងប្រាក់សោធននិវត្តន៍ដែលគាំទ្រ និងផ្តល់ថវិកាដល់សេវាផ្សេងៗសម្រាប់ជនជាតិអូស្ត្រាលី ។
នៅរៀងរាល់ឆ្នាំជនជាតិអូស្ត្រាលីភាគច្រើនបំផុតបញ្ជូនទម្រង់ទូរទាត់ពន្ធដារទៅក្រសួងពន្ធដារអូស្ត្រាលី ។

គុណតម្លៃ

គោលការណ៍ដែលជួយមនុស្សធ្វើសេចក្តីសម្រេចថាអ្វីដែលត្រូវ និងអ្វីដែលខុស ហើយរបៀបប្រព្រឹត្តនៅក្នុងស្ថានភាពផ្សេងៗ ។
ប្រទេសអូស្ត្រាលីមានកម្រងគុណតម្លៃរួមដែលយើងហៅថាគុណតម្លៃរបស់ប្រទេសអូស្ត្រាលី ។

អ្នកស្ម័គ្រចិត្ត

មនុស្សដែលផ្តល់ពេលវេលារបស់ពួកគេទៅដល់មនុស្សម្នាក់ ឬអង្គការមួយដោយមិនយកកម្រៃ ។
Raza គឺជាអ្នកស្ម័គ្រចិត្តដែលបង្រៀនភាសាអង់គ្លេសដល់មនុស្សនៅក្នុងផ្ទះរបស់ពួកគេ ។

ចប់ផ្នែកដែលអាចយកមកប្រឡង